# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ សែម សំអុល ភេទប្រុស អាយុ៥៧ឆ្នាំ

**មុខងារសម័យខ្មែរក្រហមៈ នីរសានៅឃ្លាំងអគ្គសេនាធិការ**

**ស្រុកកំណើតនៅខ្វាំង ឃុំបាក់ក្តោង ស្រុករវៀង ខេត្តព្រះវិហារ**

**រស់នៅភូមិអូររំដួល ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០១:៤២:២៦**

**៤៩ទំព័រ**

ដានីៈ លោកពូដំបូងអីចឹងខ្ញុំចង់ស្គាល់ឈ្មោះលោកពូពេញ ឈ្មោះពេញឈ្មោះអីដែរ?

អុលៈ សែម សំអុល ។

ដានីៈ «ស» ដាក់ «ែ» និង «ម», «ស» ស្រះ «ំ» «អ» ដាក់«ុ» និង«ល» ត្រូវហើយ?

អុលៈ បាទ!

ដានីៈ លោកពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

អុលៈ សព្វថ្ងៃ៥៧ហើយ ។

ដានីៈ គ្រួសារលោកពូឈ្មោះអីដែរ?

អុលៈ គុណ ធា ។

ដានីៈ ត្រកូលគាត់អីដែរ?

អុលៈ ត្រកូលគុណ ។

ដានីៈ ត្រកូលគុណ ឈ្មោះ ធា?

អុលៈ បាទ!

ដានីៈ គាត់អាយុប៉ុន្មានដែរ?

អុលៈ គាត់អាយុ៤៧ ។

ដានីៈ ហើយលោកពូមានកូនចៅប៉ុន្មាននាក់ដែរ?

អុលៈ ខ្ញុំកូន៥ ។

ដានីៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

អុលៈ ស្រី៣ ប្រុស២ ។

ដានីៈ គាត់ធំៗអស់ហើយ?

អុលៈ ធំហើយ ។

ដានី៖ បានរៀនសូត្រដល់ណាដែរ?

អុលៈ បានថ្នាក់ទី៩ បងៗពីរនាក់ មួយបានថ្នាក់ទី៩ដែរ មួយមានប្ដីហើយ មួយក៏មានប្រពន្ធទៅ

ដានី៖ អីចឹងមានប្ដី មានប្រពន្ធ២នាក់ហើយ នៅសល់៣នាក់ ៣នាក់ហ្នឹងគាត់រៀនទាំង៣?

អុលៈ រៀនតែ២ទេ ។

ដានី៖ ម្នាក់ទៀតឈប់ហើយ ឈប់ថ្នាក់ទី៩?

អុលៈ បានថ្នាក់ទី៩ចប់ឈប់ ។

ដានី៖ ពីរទៀតលោកគ្រោងឲ្យរៀនដល់ណាដែរ?

អុលៈ ចង់ឲ្យចប់ដែរ ។

ដានី៖ ចប់ត្រឹមថ្នាក់ទីប៉ុន្មាន?

អុលៈ ថ្នាក់ទី១២ ។

ដានី៖ សព្វថ្ងៃលោកពូប្រកបរបររកស៊ីធ្វើអីដែរ?

អុលៈ ខ្ញុំធ្វើតែស្រែ ចំការ ។

ដានី៖ លោកពូធ្វើជាមេភូមិតាំងពីឆ្នាំណាមក?

អុលៈ ២០០២ ។

ដានី៖ ហើយភូមិនេះគេហៅភូមិអីដែរ?

អុលៈ ភូមិអូររំដួល ។

ដានី៖ ឃុំ?

អុលៈ ឃុំព្រះប្រឡាយ ។

ដានី៖ ស្រុកអីដែរនេះ?

អុលៈ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ ។

ដានី៖ លោកពូស្រុកកំណើតលោកពូនៅភូមិ-ឃុំ ស្រុកអីដែរ?

អុលៈ នៅភូមិខ្វាំង ឃុំបាក់ក្ដោង ។

ដានី៖ ខ្វាំង សរសេរ “ខ” ជើង “្វ” “ាំ” ឃុំបាក់ក្ដោង ស្រុកអីដែរហ្នឹង?

អុលៈ ស្រុករវៀង ។

ដានី៖ ខេត្តព្រះវិហារ?

អុលៈ បាទ! ព្រះវិហារ ។

ដានី៖ លោកពូជនជាតិខ្មែរឬក៏?

អុលៈ ជនជាតិខ្មែរ ។

ដានីៈ ខ្មែរសុទ្ធ?

អុលៈ បាទ!

ដានីៈ ឪពុកលោកពូគាត់ឈ្មោះអីដែរ?

អុលៈ ស្លាប់អស់ហើយពុកខ្ញុំ ។

ដានីៈ គាត់ឈ្មោះអីដែរទៅ?

អុលៈ ឈ្មោះ ធួន ។

ដានីៈ គាត់ស្លាប់ហើយ ស្លាប់តាំងពីអង្កាល់?

អុលៈ ស្លាប់តាំងពីឆ្នាំ៦០ ។

ដានីៈ គាត់ស្លាប់ដោយសារមូលហេតុអី?

អុលៈ គាត់ឈឺ គាត់ចាស់ ។

ដានីៈ ម្ដាយ?

អុលៈ ម្ដាយឈ្មោះជួន ស្លាប់ ។

ដានីៈ គាត់ស្លាប់ដែរ?

អុលៈ បាទ!

ដានីៈ គាត់ស្លាប់តាំងពីអង្កាល់ដែលទៅ?

អុលៈ ស្លាប់ឆ្នាំ៧៣ ។

ដានីៈ ដោយសារមូលហេតុអីដែរ?

អុលៈ គាត់ឈឺចាស់ហើយ ។

ដានីៈ អីចឹងលោកពូបងប្អូនប៉ុន្មាននាក់ទៅ?

អុលៈ ខ្ញុំបងប្អូន៣នាក់ ។

ដានីៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅ?

អុលៈ ស្រី១ ប្រុស២ ។

ដានីៈ លោកពូកូនពៅគេ?

អុលៈ ពៅគេបង្អស់ ។

ដានីៈ បងៗគាត់ចាស់ៗហើយឥឡូវ?

អុលៈ ចាស់ៗ បងមួយស្លាប់បាត់ នៅតែបងស្រីមួយ និងខ្ញុំប៉ុណ្ណឹង សព្វថ្ងៃនៅតែ២នាក់ បងស្រីនៅស្រុកនោះ ។

ដានីៈ លោកពូនៅនេះ?

អុលៈ ខ្ញុំនៅនេះ ។

ដានីៈ លោកពូកាលពីក្មេងៗ បានរៀនសូត្រដល់ណាដែរ?

អុលៈ ខ្ញុំពីសង្គមត្រឹមថ្នាក់ទី១០ ។

ដានីៈ រៀននៅណាថ្នាក់ទី១០?

អុលៈ រៀននៅស្រុក ។

ដានីៈ កាលនៅស្រុក?

អុលៈ បាទ!

ដានីៈ ហើយកាលពីក្មេងលោកពូមានដែលមានបំណងប្រាថ្នាអី ចង់រៀនសូត្រដល់ណា មានការស្រមើលសៃម៉ៃចង់ធ្វើការងារអីដែរ ឬអត់ទេ?

អុលៈ កាលនោះចង់រៀន ដល់ស្រុកកើតសង្គ្រាម គេរើសធ្វើកងទ័ពក៏ចូលកងទ័ព ។

ដានីៈ កាលពីក្មេងចង់រៀនដែរ? ចង់រៀនដល់ណាដែរ?

អុលៈ ចង់រៀនដល់ថ្នាក់ទី៧-៨ពីសង្គម ដល់ស្រុកកើតសង្គ្រាមទៅលែងបានរៀន ធ្វើកងទ័ព ។

ដានីៈ លោកពូឈប់ឆ្នាំណាទៅហ្នឹង?

អុលៈ ឈប់រៀន?

ដានីៈ បាទ!

អុលៈ ឈប់រៀនពីឆ្នាំ៦៦-៦៧ ។

ដានីៈ ឈប់រៀន៦៦-៦៧?

អុលៈ បាទ!

ដានីៈ កាលរៀននៅក្នុងសាលាណាទៅ?

អុលៈ ខ្ញុំរៀនវត្ត ។

ដានីៈ វត្តអីគេ?

អុលៈ វត្តខ្នាំ ។

ដានីៈ ខ្នាំនៅជិតទីរួមស្រុករៀងដែលឬឆ្ងាយ?

អុលៈ អត់ឆ្ងាយទេ ៣-៤គីឡូពីទីរួមស្រុក ។

ដានីៈ កាលពីជំនាន់ពូនៅក្មេងៗ រវៀងហ្នឹងទីរួមខេត្តព្រះវិហារតែម្តង ឬយ៉ាងម៉េច?

អុលៈ ទីរួមស្រុក ។

ដានីៈ ទីរួមខេត្តនៅណាទៅ?

អុលៈ ទីរួមខេត្តនៅកំពង់ប្រណាក ។

ដានី៖ នៅកន្លែងរាល់ថ្ងៃហ្នឹងឬអត់ទេ?

អុល៖ នៅកន្លែងរាល់ថ្ងៃហ្នឹង ។

ដានី៖ ត្បែងមានជ័យហ្នឹង?

អុល៖ បាទ!

ដានី៖ កាលពីលោកពូនៅក្មេងៗក៏អីចឹងដែរ?

អុល៖ បាទ! អីចឹង ។

ដានី៖ រវៀងជាទីរួមស្រុកទេ?

អុល៖ បាទ! ព្រោះខេត្តព្រះវិហារបំបែកចេញពីខេត្តកំពង់ធំ ។

ដានី៖ បំបែកឆ្នាំណាលោកពូចាំទេ?

អុល៖ អត់ចាំទេ ។

ដានី៖ ដល់ឆ្នាំ៦៦-៦៧លោកពូឈប់រៀនធ្វើអីទៅ?

អុល៖ កាលហ្នឹងខ្ញុំនៅធ្វើស្រែដែរ ដល់ឆ្នាំ៧២បានចូលធ្វើកងទ័ព ។

ដានី៖ ធ្វើស្រែជាមួយឪពុកម្ដាយទេ?

អុល៖ បាទ!

ដានី៖ កាលពេលលោកពូឈប់រៀន៦៦-៦៧ ឪពុកលោកពូគាត់ស្លាប់?

អុល៖ គាត់ស្លាប់យូរហើយ ស្លាប់តាំងពី៦៣ ពុកខ្ញុំស្លាប់ ។

ដានី៖ អីចឹង៦៦-៦៧ធ្វើស្រែ ដល់ឆ្នាំ៧២?

អុល៖ ចូលកងទ័ព ។

ដានី៖ លោកពូនៅចាំថាម៉េចបានយើងចូលកងទ័ព ហើយចូលកងទ័ពខាងណាទៅ?

អុល៖ ចូលខាងព្រៃ ។

ដានី៖ ខាងខ្មែរក្រហម?

អុល៖ បាទ!

ដានី៖ កាលហ្នឹងមានចលនាអីខ្លះធ្វើឲ្យលោកពូចូលកងទ័ព ចូលព្រៃជាមួយខ្មែរក្រហម?

អុល៖ កាលហ្នឹងវីលន់ នល់ ។

ដានី៖ កាលហ្នឹងលោកពូចូលម្នាក់ឯង ឬមានយុវជន យុវនារី ដំណាលៗលោកពូ ក្មេងជាង ឬអាយុច្រើនជាងចូលទៅច្រើនអត់នៅក្នុងភូមិស្រុករបស់លោកពូ?

អុល៖ ច្រើនដែល៨-១០នាក់ ។

ដានី៖ ចូលទៅដំណាលគ្នាហ្នឹង?

អុលៈ បាទ! ជំណាលគ្នា ។

ដានីៈ ចូលទៅនៅកន្លែងណាជំបូង?

អុលៈ ចូលជំបូងនៅទីរួមស្រុកមួយឆ្នាំ ។

ដានីៈ កាលហ្នឹងទីរួមស្រុកខ្មែរក្រហមគេនៅ ឬខាងលន់ នល់នៅ?

អុលៈ កាលហ្នឹងខាងលន់ នល់ តែយើងនៅក្នុងព្រៃ យើងតស៊ូនៅក្នុងព្រៃ ។

ដានីៈ តែគេចាត់ទុកមានស្រុកដែរ?

អុលៈ បាទ! ចាត់ទុកមានស្រុកដែរ ។

ដានីៈ គេរៀបចំជាស្រុកដែរ?

អុលៈ បាទ!

ដានីៈ មានគណៈគ្រប់គ្រងជាចៅហ្វាយស្រុកមានដែរ?

អុលៈ មាន ។

ដានីៈ កាលហ្នឹងពីណាគេចៅហ្វាយស្រុក?

អុលៈ កាលហ្នឹងឈ្មោះសាង តែត្រកូលគេអត់ស្គាល់ទេ ។

ដានីៈ នៅស្រុករវៀងហ្នឹង?

អុលៈ បាទ!

ដានីៈ កាលហ្នឹងគេមានស្រុក គេមានតំបន់ដែរ?

អុលៈ មាន ។

ដានីៈ តំបន់ប៉ុន្មានទៅកាលហ្នឹង?

អុលៈ តំបន់១០៣ ។

ដានីៈ ពីឆ្នាំ៧២មានហើយ?

អុលៈ ឆ្នាំ៧២មាន ។

ដានីៈ ១០៣គណៈតំបន់គេពីណាគេ?

អុលៈ តាហង់ ។

ដានីៈ តាហង់ គាត់គ្រប់គ្រងតាំងពីឆ្នាំ៧២មក?

អុលៈ បាទ!

ដានីៈ ដែលឃើញគាត់ដែរ?

អុលៈ អត់ដែលឃើញទេ ។

ដានីៈ លោកពូចូលទៅយើងនៅខាងស្រុកគេមួយឆ្នាំ កាលហ្នឹងលោកពូធ្វើអីគេទៅមួយឆ្នាំ?

អុលៈ ធ្វើយុទ្ធជនធម្មតា ។

ដានីៈ នៅក្នុងកងយោធាស្រុក ឬក៏អត់ទេ?

អុលៈ យោធាស្រុក ។

ដានីៈ ដល់ពេលមួយឆ្នាំហើយយ៉ាងម៉េចទៀត?

អុលៈ មួយឆ្នាំហើយគេបញ្ជូនទៅសមរភូមិ ។

ដានីៈ ឆ្នាំណាហ្នឹង? ជិតប៉ុន្មានទៅ?

អុលៈ ៧៣ ។

ដានីៈ បញ្ជូនលោកពូទៅខាងណាវិញទៅ?

អុលៈ បញ្ជូនទៅវ៉ៃនៅកំពង់ធំ ភ្នំពេញ ។

ដានីៈ វ៉ៃកំពង់ធំហើយ វ៉ៃភ្នំពេញទៀត?

អុលៈ បាទ! វ៉ៃកំពង់ធំ ភ្នំពេញ ។

ដានីៈ ពីឆ្នាំ៧៣បញ្ជូនលោកពូទៅខាងកំពង់ធំយើងចូលក្នុងកងអីវិញ?

អុលៈ ហ្នឹងចូលកងពល ។

ដានីៈ ចូលកងពលណាទៅ?

អុលៈ ៨០៤ ។

ដានីៈ ហ្នឹងកងពលនៅ៨០៤ហ្នឹង?

អុលៈ បាទ! កងពល ។

ដានីៈ កងពលរបស់ពីណាគេ៨០៤?

អុលៈ បងភ្លេចឈ្មោះគាត់បាត់ មិនមែន៨០៤ទេ កងពលមុន ។

ដានីៈ ប្រធានកងពលឈ្មោះអីគេ?

អុលៈ ប្រធានកងពលឈ្មោះ សឿន ។

ដានីៈ ព្រោះដំបូងយើងចូលទៅចូលក្នុងកងពលភូមិភាគ ឬមជ្ឈិម?

អុលៈ របស់ភូមិភាគ ។

ដានីៈ ភូមិភាគកណ្ដាល ឬភូមិភាគឧត្តរ?

អុលៈ ភូមិភាគឧត្តរ ។

ដានីៈ ព្រោះកាលហ្នឹងភូមិភាគឧត្តរមាន៣កងពល មានកងពលទី១, កងពលទី២, កងពលទី៣ កងពលទី១កងពលរបស់តាអឿន, កងពលទី២របស់សួង ហើយហ៊ាន, កងពលទី៣ឈ្មោះ

ឈិន ហើយនិងសយ ហ្នឹងកងពលរបស់ភូមិភាគឧត្ដរ ដែលមានកំពង់ចាម, កំពង់ធំ, សៀមរាប ព្រះវិហារដែលអត់?

អុលៈ បាទ! សៀមរាប, ព្រះវិហារ, កំពង់ធំ ។

ដានីៈ លោកពូនៅក្នុងកងពលមួយណាទៅ?

អុលៈ នៅកាលហ្នឹង មិនមែន ។

ដានីៈ មិនមែនកងពលហ្នឹងទេ?

អុលៈ នៅហ្នឹងហើយ កងពលហ្នឹងនៅប្រចាំ តែកាលហ្នឹងចូលកងពលតែខ្ញុំនៅវរសេនាធំ ។

ដានីៈ វរសេនាធំរបស់ពីណាគេ?

អុលៈ វរសេនាធំរបស់តាសឿន ៥២ ។

ដានីៈ កងពលទីប៉ុន្មាន?

អុលៈ កងពលទី២ ។

ដានីៈ របស់តាណា?

អុលៈ អីពូថាម៉ិញ?

ដានីៈ មានតាសួង ។

អុលៈ តាសួង កងពលទី២ ។

ដានីៈ វ៉ៃដំបូងវ៉ៃកំពង់ធំទេ ។

អុលៈ បាទ!

ដានីៈ ឆ្នាំណាដែលយើងវ៉ៃទៅភ្នំពេញ?

អុលៈ វ៉ៃដេញទាល់តែឈ្នះភ្នំពេញ ។

ដានីៈ ដល់ពេលទៅភ្នំពេញយើងចូលទៅតាមខាងណា? ចូលតាមណា?

អុលៈ បាទ?

ដានីៈ យើងវ៉ៃចូលភ្នំពេញតាមណា?

អុលៈ តាមផ្លូវជាតិលេខ៦ ។

ដានីៈ ចូលច្រកណាទៅ?

អុលៈ មិនសូវចំណាំទេ ។

ដានីៈ ដល់ពេលយើងវ៉ៃចូលភ្នំពេញ ឈ្នះទីក្រុងភ្នំពេញហើយកងពលលោកពូចូលទៅនៅណា?

អុលៈ កាលហ្នឹងចេញពីហ្នឹងគេដាក់ទៅព្រំដែនយួនវិញ ទៅនៅមុំអ្នកលឿង ។

ដានី: ពេលដែលយើងឈ្នះភ្នំពេញថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ កងពលរបស់លោកពូទៅខាងអ្នកលឿងវិញ?

អុលៈ បាទ!

ដានី: នៅក្នុងកងពលលេខប៉ុន្មានវិញ?

អុលៈ នៅ៨០២ ។

ដានី: កាលហ្នឹងមាន៨០២ដែរ?

អុលៈ មាន ។

ដានី: កាលហ្នឹងមានកងពល៣១០, កងពល៤៥០, កងពល១៧០, កងពល២៩០ ។

អុលៈ ៨០២គេនៅនេះទេ អត់សូវចំណាំទេខ្ញុំ ។

ដានី: ពីណាប្រធានកងពល?

អុលៈ អត់ស្គាល់គេផង ។

ដានី: ទៅនៅហ្នឹងបានយូរទេ?

អុលៈ នៅបានមួយខែ គេដកខ្ញុំមកភ្នំពេញវិញ ។

ដានី: ម៉េចទៀតទៅ?

អុលៈ មកភ្នំពេញខ្ញុំមកនៅជាមួយឪពុកមាខ្ញុំ មុខទន្លេ នៅកន្លែងមន្ទីរ ។

ដានី: មន្ទីរអីគេហ្នឹង?

អុលៈ មន្ទីរ យើងធម្មតា មន្ទីរអគ្គរក្ស ។

ដានី: ការពារពីណាគេ? គេហៅមន្ទីរអីគេទៅ?

អុលៈ ការពារកន្លែងឃ្លាំងគ្រាប់ ឃ្លាំងកាំភ្លើង ។

ដានី: កាលហ្នឹងនៅការពារអីៗ ឬ?

អុលៈ អត់ទេ ការពារឃ្លាំងគ្រាប់ ឃ្លាំងកាំភ្លើង ។

ដានី: ឃ្លាំងគ្រាប់ ឃ្លាំងកាំភ្លើងរបស់អគ្គសេនាធិការ ឬក៏របស់កងពល?

អុលៈ របស់កងពល ។

ដានី: នៅការពារឃ្លាំង តាឡូ គាត់ប្រធាន?

អុលៈ កាលហ្នឹងគាត់ប្រធានឃ្លាំង ។

ដានី: នៅកន្លែងណា? នៅម្តុំណា?

អុលៈ នៅទួលគោក ។

ដានី: ឃ្លាំងរបស់កងពលណាទៅ?

អុលៈ	មិនមែនរបស់កងពលទេ របស់អគ្គ កន្លែងរួមតែម្តង រួមទូទាំងប្រទេស ។

ដានីៈ	កន្លែងអគ្គរបស់អ៊ឹសុន សេន?

អុលៈ	ហ្នឹងហើយរបស់តាសុន សេន ។

ដានីៈ	ពូស្គាល់តាសុន សេន អត់ពេលហ្នឹង?

អុលៈ	ស្គាល់តែឈ្មោះ តែអត់ទាន់ឃើញមុខ មាត់នឹងគេ ។

ដានីៈ	អីចឹងលោកពូមកនៅកន្លែងឃ្លាំងហ្នឹងវិញ នៅជាមួយតាឡេ?

អុលៈ	បាទ! នៅជាមួយឪពុកមាខ្ញុំ ។

ដានីៈ	ឪពុកមានៅដល់ពេលណាទៅ?

អុលៈ	នៅរហូតដល់យួនចូលស្រុក ។

ដានីៈ	នៅហ្នឹងរហូត?

អុលៈ	បាទ!

ដានីៈ	កាលហ្នឹងធ្វើអីខ្លះទៅ ពេលយើងនៅភ្នំពេញ?

អុលៈ	គ្មានធ្វើអីទេ នៅនីរសាគាត់ នៅចាំឃ្លាំង គេត្រូវការគ្រាប់កាំភ្លើងយើងចាក់ឃ្លាំងឲ្យគេ ។

ដានីៈ	នៅក្នុងហ្នឹងក្រៅពីឪពុកមាលោកពូមានពីណាខ្លះទៀត?

អុលៈ	មិនដឹងពីណាខ្លះទៀត ខ្ញុំអត់សូវស្គាល់ ភ្លេចគ្នាយូរហើយ ។

ដានីៈ	ឃ្លាំងហ្នឹងនៅទួលគោក?

អុលៈ	បាទ!

ដានីៈ	នៅគ្នាច្រើនទេលោកពូ?

អុលៈ	នៅ១០-២០នាក់ ។

ដានីៈ	ហើយឪពុកមាលោកពូឥឡូវគាត់នៅណា?

អុលៈ	ស្លាប់បាត់ហើយ ស្លាប់ពី៨១-៨២ ។

ដានីៈ	ពេលរត់មក?

អុលៈ	មិនមែនប៉ែតទេ ៧៦-៧៧ ។

ដានីៈ	គេចាប់គាត់ឬក៏ម៉េច?

អុលៈ	ចាប់អីគាត់ស្លាប់បាញ់គ្នា មកស្លាប់លើភ្នំ ។

ដានីៈ	ស្លាប់លើភ្នំ ៨៦-៨៧?

អុលៈ	បាទ! ៨៦-៨៧ ។

ដានីៈ	កាលហ្នឹងគាត់ធ្វើអី មុនស្លាប់?

អុលៈ គាត់កងពល ។

ដានីៈ កងពលជាមួយពីណាគេ?

អុលៈ កងពលជាមួយ៦១៦ ជាមួយតាញ៉ែន ។

ដានីៈ ជាមួយតាញ៉ែន?

អុលៈ បាទ!

ដានីៈ គាត់ប្រធាន ឬយ៉ាងម៉េច?

អុលៈ គាត់សមាជិកគេទេ ស្លាប់ឪពុកមាខ្ញុំទៅបានគេបំបែកអ្នកព្រះវិហារហ្នឹងឲ្យមកនៅ៦១៧ វិញ ។

ដានីៈ អ៊ីចឹងឪពុកមាលោកពូគាត់អ្នកព្រះវិហារដែរ?

អុលៈ អ្នកព្រះវិហារ ។ ប្អូនតាមេឃុំចាស់ហ្នឹង ។

ដានីៈ ប្អូនតា?

អុលៈ តាគឿន ។

ដានីៈ អ៊ីចឹងមេឃុំចាស់ក៏ត្រូវជាឪពុកមា?

អុលៈ ឪពុកមា ។

ដានីៈ អ៊ីចឹងនៅភ្នំពេញរហូត?

អុលៈ បាទ! ជិនាន់៣ឆ្នាំនៅហ្នឹងរហូត ។

ដានីៈ នៅឃ្លាំងហ្នឹងទៅ?

អុលៈ នៅឃ្លាំងរហូត ។

ដានីៈ ពេលដែលយើងមានសង្គ្រាមជាមួយយួន ត្រូវជញ្ជូនគ្រាប់យ៉ាងម៉េចខ្លះទៅ?

អុលៈ កាលហ្នឹងឡានគេដឹកជញ្ជូន ឡានគេមាន ។

ដានីៈ លោកពូដែលយកគ្រាប់ទៅឲ្យគេនៅសមរភូមិដែលអត់?

អុលៈ អត់ទេ ឡានគេមកយកគេដឹកទៅខ្លួនគេ ទៅដឹកនៅឃ្លាំង មើលលើការខុសត្រូវឃ្លាំង ។

ដានីៈ គ្រាន់តែមើលការខុសត្រូវទេ?

អុលៈ គេត្រូវការ ឡានមកយើងលើកដាក់ ។

ដានីៈ ទាល់តែមានសំបុត្រអ៊ីត្រឹមត្រូវបានយើងឲ្យ?

អុលៈ បាទ! មាន ។

ដានីៈ ទាល់តែសំបុត្រចេញពីណាបានឲ្យ?

អុលៈ សំបុត្រចេញពីអគ្គ កងពលណាៗស្នើរសុំសំបុត្រចេញពីអគ្គមកបានបើក ។

ដានី:		កាលហ្នឹងលោកពូចាំទេ មានប៉ុន្មាននកងពល?

អុលៈ		អត់សូវចាំទេ ។

ដានី:		កាលហ្នឹងតាមុត, តាម៉េត គាត់នៅអគ្គដែរ ឬអត់ទេ?

អុលៈ		នៅអគ្គតាមុត, តាម៉េត ។

ដានី:		ពីណាទៀតនៅអគ្គក្រៅពីតាសុន សេន, ចុះតាអ៊ុង វ៉ែន នេះគាត់នៅអគ្គដែរ?

អុលៈ		អត់ទេ ខ្ញុំអត់សូវចំណាំផង ។

ដានី:		ស្គាល់តាណាត ទេ?

អុលៈ		តាណាត លឺតែឈ្មោះទេ មិនដែលឃើញមុខមាត់ទេ ។

ដានី:		កាលហ្នឹងលោកពូធ្លាប់មកលេងផ្ទះទេកាលយើងនៅភ្នំពេញ?

អុលៈ		អត់ដែលមកទេខ្ញុំ ។

ដានី:		កាលនោះលោកពូមានប្រពន្ធនៅកាលនៅភ្នំពេញ?

អុលៈ		នៅទេ ។

ដានី:		អត់ទាន់មានទេ?

អុលៈ		អត់ ទើបតែយកឆ្នាំ៨៤ មកលើភ្នំហើយ ។

ដានី:		ហើយឪពុកមាលោកពូដែលគាត់មេឃុំចាស់ហ្នឹងគាត់នៅភ្នំពេញដែលកាលពី?

អុលៈ		អត់ទេ គាត់នៅស្រុកនេះ គាត់ទើបតែមក៧៩ហើយ ។

ដានី:		កាលហ្នឹងទៅនៅជាមួយឪពុកមាតែលោកពូម្នាក់ទេ?

អុលៈ		បាទ!

ដានី:		ទៅចូលទ័ពកាលពីឆ្នាំ៧២តាមគាត់ដែរ?

អុលៈ		អត់បានតាមគាត់ទេ ទើបតែគេវៃដាច់ភ្នំពេញទើបជួបគាត់ ។

ដានី:		ឪពុកមាបង្កើត?

អុលៈ		ឪពុកមាបង្កើត ។

ដានី:		កាលមុនគាត់នៅតស៊ូនៅណាទៅអីចឹង?

អុលៈ		កាលមុននៅកងពលណាទេ ។

ដានី:		គាត់នៅជាមួយខត្តរដែលអត់ទេ?

អុលៈ		នៅខត្តរដែរ ។

ដានី:		គាត់នៅខាងកាំភ្លើងធំឬអត់ទេ? ខាងកាំភ្លើងធំ ខាងរថក្រោះ មិនមែនទេ?

អុលៈ		អត់ទេ ។

ដានី: កាលហ្នឹងនៅអគ្គសេនាធិការមានខាងកងកាំភ្លើងធំ មានកងរថក្រោះផ្សេងទៀត?

អុលៈ ផ្សេងទៀត ខ្ញុំនៅជាមួយគាត់យាមតែឃ្លាំងគ្រាប់ ឃ្លាំងរំសេវ ។

ដានី: ហើយគាត់ប្រធានឃ្លាំងហ្នឹង?

អុលៈ គាត់ប្រធានឃ្លាំង ។

ដានី: ឈ្មោះតាឡេ ឈ្មោះពេញគាត់ឈ្មោះអីទៅ?

អុលៈ ឈ្មោះគាត់ពីដើមឈ្មោះឆោម ។

ដានី: ឡេ គាត់ដូរឆ្នាំណា?

អុលៈ មិនដឹងដូរពីឆ្នាំណា ជួបគាត់នៅជាមួយគាត់ហៅតាឡេៗ រហូត ។

ដានី: កាលនៅភ្នំពេញគេហៅតាឡេ?

អុលៈ បាទ!

ដានី: គេអត់ហៅតាឆោម ទេ?

អុលៈ អត់ទេ គេហៅឈ្មោះថ្មីគាត់ ផ្លាស់តាំងពីចេញពីស្រុកទៅ គាត់ផ្លាស់ក៏មិនដឹង ។

ដានី: កាលហ្នឹងនៅភ្នំពេញសប្បាយអត់លោកតូ?

អុលៈ មានអីសប្បាយ ។

ដានី: ហូបចុកអីគ្រប់គ្រាន់ដែរ?

អុលៈ បាទ! ធម្មតា ។

ដានី: ប៉ុន្មានពេលមួយថ្ងៃ?

អុលៈ មួយថ្ងៃ៣ពេល ។

ដានី: ហូបបាយ?

អុលៈ ហូបបាយ ។

ដានី: សម្លអីមានសាច់គ្រប់?

អុលៈ មានសាច់ មានត្រីធម្មតា ។

ដានី: យើងអាចដើរលេង មើលគេ មើលឯងនៅភ្នំពេញ?

អុលៈ ដើរបាន ។

ដានី: កាលហ្នឹងមនុស្សច្រើនទេនៅទីក្រុងភ្នំពេញ?

អុលៈ ច្រើន ដូចជាសព្វថ្ងៃនេះអីចឹង ។

ដានី: អត់ដែលឃើញអ៊ំនួន ជា, អ៊ំប៉ុល ពត?

អុលៈ អត់ អត់ដែលឃើញ ។

ដានី៖ កងទ័ពច្រើនអត់នៅភ្នំពេញកាលជំនាន់៣ឆ្នាំលោកពូនៅ?

អ៊ុល៖ ច្រើនដែលកងទ័ព ។

ដានី៖ កងទ័ពគេធ្វើអីនៅភ្នំពេញ?

អ៊ុល៖ មិនធ្វើអី ធ្វើស្រែ កន្លែងណាស្រែក៏ស្រែ ការពារ ។

ដានី៖ ឃ្លាំងគ្រាប់ហ្នឹងនៅទួលគោកនៅម្តុំណាលោកពូ?

អ៊ុល៖ ខ្ញុំវង្វេងអស់ហើយសព្វថ្ងៃ ។

ដានី៖ ព្រោះទួលគោកយើងមានអង់តែនទូរទស្សន៍មួយ ឃ្លាំងគ្រាប់នៅក្បែរហ្នឹង ឬនៅពីខាងណាអង់តែនហ្នឹង?

អ៊ុល៖ នៅខាងលិចឆៀងខាងជើង ។

ដានី៖ ខាងលិចឆៀងខាងជើង ខាងពាយ័ព្យ ។ ខាងឆ្ងាយពីអង់តែនទេ?

អ៊ុល៖ ឆ្ងាយ ប្រហែលកន្លះគីឡូ ។

ដានី៖ ជិតមាត់ទន្លេវិញ ឬអត់ទេ?

អ៊ុល៖ ជិត ។

ដានី៖ ស្គាល់ស្ពានទួតបារាំងទេកាលនោះ?

អ៊ុល៖ អត់ទេ ។

ដានី៖ ស្គាល់ស្តាតចាស់ទេ?

អ៊ុល៖ អត់ ។

ដានី៖ ស្គាល់ស្ពានជ្រោយចង្វារ?

អ៊ុល៖ អីមិនស្គាល់ស្ពានជ្រោយចង្វារ នៅខាងលិចស្តាត ឃ្លាំងនៅខាងលិច ខ្ញុំមិនចាំវង្វេងអស់នៅអត់សូវបានដើរ ។

ដានី៖ អ្នកនៅជាមួយពីដំបូងហ្នឹងនៅជាមួយគ្នារហូត ឬមានការផ្លាស់ប្តូរទៅណាទេ?

អ៊ុល៖ ពួកខ្ញុំអត់មានផ្លាស់ប្តូរទេ មានតែចេញឃួនចូលបែកគ្នារហូត ។

ដានី៖ ឪពុកមាលោកពូកាន់នៅឃ្លាំងហ្នឹងកាន់តាំងពីដំបូងមករហូតរត់ឃួន?

អ៊ុល៖ បាទ!

ដានី៖ អត់មានគេផ្លាស់ប្តូរធ្វើអី?

អ៊ុល៖ អត់ទេ ចេញពីនោះមកៗរហូត ។

ដានី៖ គាត់មានប្រពន្ធទេកាលនោះ?

អ៊ុល៖ មាន ។

ដានី: ប្រពន្ធគាត់នៅទេឥឡូវ?

អុលៈ ប្រពន្ធគាត់នៅ ប្រពន្ធគាត់មុនរត់មកបែកបាក់គ្នា ដល់គាត់លើភ្នំគាត់យកប្រពន្ធមួយទៀត

ដានី: ប្រពន្ធគាត់នៅណា?

អុលៈ ប្រពន្ធគាត់នៅពោធិ៍សាត់ ។

ដានី: ឥឡូវទៅនៅពោធិ៍សាត់វិញ?

អុលៈ បាទ!

ដានី: ចុះប្រពន្ធមុនបែកបាក់គ្នា?

អុលៈ បែកបាក់គ្នារហូតរកអត់ឃើញ ។

ដានី: មានកូនដែរ?

អុលៈ អត់ ។

ដានី: ឈ្មោះអីគេប្រពន្ធមុន?

អុលៈ ឈ្មោះភឿន ។

ដានី: ដល់ប្រពន្ធក្រោយមានកូនទេ?

អុលៈ ក្រោយបានកូនមួយ ។

ដានី: ប្រពន្ធក្រោយឈ្មោះអី?

អុលៈ ឈ្មោះពៅ ។

ដានី: ចុះកូន?

អុលៈ កូនទៅតាមម្ដាយ គាត់យកប្ដីទៀតទៅ ។

ដានី: កាលហ្នឹងឪពុកមាលោកពូក្មេងដែរ ឬក៏ចាស់ហើយកាលពេលលោកពូនៅជាមួយ?

អុលៈ នៅក្មេងដែរ ។

ដានី: អាយុច្រើនជាងលោកពូប៉ុន្មានឆ្នាំ?

អុលៈ ច្រើនណាស់ គាត់ចូល៣០-៤០ហើយ ។

ដានី: កាលហ្នឹង៣០-៤០ លោកពូអាយុប៉ុន្មាន?

អុលៈ ខ្ញុំទើប១៨-១៩ ។

ដានី: នៅក្មេងដែរ?

អុលៈ បាទ!

ដានី: លោកពូខស្បាហ៍បានដើរទស្សនកិច្ចអីដែរ?

អុលៈ អត់ទេ មិនដែលបានដើរទៅណាទេ ។

ដានី: មានថតរូបដែលអត់កាលជំនាន់នោះ?

អុល: អត់ៗ

ដានី: សំបូររបស់ហូបចុកដែរ?

អុល: សំបូរ ផ្លែឈើអត់អីទេៗ

ដានី: យើងទៅយកពីណាផ្លែឈើ?

អុល: គេដឹកទៅឲ្យៗ

ដានី: អត់ដែលមកលេងផ្ទះ អត់នឹក?

អុល: នឹក បងប្អូនម៉ែឪនឹក ឪពុកម្ដាយខ្ញុំក៏មិនដែលមកៗ

ដានី: គាត់អត់ដែលមកដែរ?

អុល: អត់ដែលមកៗ

ដានី: កាលនៅឃុំជួបគ្នារាល់ថ្ងៃ?

អុល: បាទ! ជួបគ្នារាល់ថ្ងៃៗ

ដានី: គាត់មានដែលនិយាយអីជាមួយលោកពូដែរ?

អុល: អត់ទេ អត់ដែលនិយាយអី គ្រាន់តែគាត់ណែនាំថាធ្វើម៉េចឲ្យត្រឹមត្រូវ កុំភ្លើតភ្លើនៗ

ដានី: គាត់ថាអីចឹងដែរ?

អុល: បាទ! ធ្វើអីមើលគេ មើលឯងៗ

ដានី: គាត់ខ្លាចយើងធ្វើអីផ្ដេសផ្ដាសគេចាប់ៗ

អុល: បាទ! ខ្លាចយើងធ្វើកន្លែងណាមួយដែលមិនគប្បី ខុសគេចាប់ចងៗ

ដានី: កាលហ្នឹងពូដែលឃើញគេចាប់ចងដែរ?

អុល: អត់ទេ អត់ដែលឃើញទេ កន្លែងនោះអត់ដែលឃើញអ្នកណាបាត់ទៅណាទេៗ

ដានី: អត់ដែលឃើញទេ?

អុល: អត់ដែលឃើញៗ

ដានី: អ្នកនៅកន្លែងហ្នឹងច្រើនតែអ្នកនៅព្រះវិហារជាមួយលោកពូដែរ ឬអត់ទេ?

អុល: អ្នកព្រះវិហារតែ៣នាក់ទេៗ

ដានី: ពីណាខ្លះ?

អុល: ខ្ញុំ, ឪពុកម្ដាយ និងណោតៗ

ដានី: ណោត ហ្នឹងគាត់នៅណាឥឡូវ?

អុល: ណោត ស្លាប់បាត់ៗ

ដានី៖ ស្គាប់តាំងពីអង្កាល់?

អុល៖ ស្គាប់យូរហើយ តាំងពីមុនអ៊ុនតាក់ទៀត ។

ដានី៖ ស្គាប់មកដល់នេះហើយ?

អុល៖ បាទ!

ដានី៖ ដល់ពេលយួនចូលឆ្នាំ៧៩យ៉ាំងម៉េចទៅលោកពូ? យើងពេលយួនចូលមកដល់ភ្នំពេញ ដំណើរទំនងលោកពូ?

អុល៖ យួនចូលដល់ភ្នំពេញអត់មានអី រត់ចេញមក ។

ដានី៖ ចេញមកតាមណា?

អុល៖ តាមផ្លូវជាតិលេខ៦ ។

ដានី៖ តាមផ្លូវជាតិលេខ៦មកតាមណាទៀត?

អុល៖ មកបន្ទាយមានជ័យ ។

ដានី៖ ផ្លូវជាតិលេខ៦ ឬផ្លូវជាតិលេខ៥?

អុល៖ ផ្លូវជាតិលេខ៦ចេញពីនោះមកកំពង់ធំ មកសៀមរាប ធ្លាក់មកផ្លូវ៦៨នេះ ។

ដានី៖ អីចឹងរត់មកតាមកំពង់ធំ?

អុល៖ បាទ!

ដានី៖ អត់តាមកំពង់ឆ្នាំង-ពោធិ៍សាត់ទេ?

អុល៖ អត់ទេ ។

ដានី៖ កាលរត់មក រត់មកជាមួយពីណាខ្លះ?

អុល៖ មកច្រើនណាស់ មកដល់ផ្លូវបារាំងហ្នឹងបោលឡាន ។

ដានី៖ បោលឡាននៅណា?

អុល៖ បោលឡានតាមផ្លូវ ផ្លូវបារាំងចាស់គេ ។

ដានី៖ កាលហ្នឹងលោកពូជិះឡានមក?

អុល៖ មកឡាន ។

ដានី៖ មកឡានជាមួយពីណាខ្លះ?

អុល៖ មកជាមួយឪពុកមាខ្ញុំ និងក្រុមគ្នា២០នាក់ ។

ដានី៖ ២០នាក់ជិះមួយឡានមក?

អុល៖ ឡាន ។

ដានី៖ ឡានអីគេ?

អុលៈ ស៊ីលចិន ។

ដានីៈ ស៊ីល?

អុលៈ ឡានរបស់ចិន មកចោលផ្លាក់ផ្លូវទៅណាអត់រួចចោល ។

ដានីៈ ជិះពីភ្នំពេញមកចោលក្នុងខេត្តណា? ផ្លូវបារាំងចាស់ហ្នឹង?

អុលៈ ខេត្តបន្ទាយមានជ័យយើង អ៎! ខេត្តឧត្តរមានជ័យយើងនេះ ។

ដានីៈ មកដល់ឧត្តរមានជ័យ?

អុលៈ បាទ!

ដានីៈ អីចឹងឡានបើកមកដល់កំពង់ធំ ចេញពីកំពង់ធំទៅសៀមរាប?

អុលៈ ទៅសៀមរាប ចេញពីសៀមរាបមកផ្លូវ៦៨វិញ ។

ដានីៈ មកផ្លូវ៦៨ឈប់នៅកន្លែងណា?

អុលៈ ជិតស្ពាច់នេះ ត្រង់ហ្នឹងចោលរហូត ។

ដានីៈ ដល់ពេលជិតស្ពាច់យើងចេញមកនៅណាទៀត?

អុលៈ ឡើងលើភ្នំ ។

ដានីៈ ឡើងលើភ្នំវិញ?

អុលៈ បាទ!

ដានីៈ អីចឹងពីភ្នំពេញដល់កន្លែងចោលឡានប៉ុន្មានថ្ងៃបានមកដល់កន្លែងហ្នឹង?

អុលៈ ២ថ្ងៃ ។

ដានីៈ ឈប់កន្លែងណាខ្លះទៅ?

អុលៈ ឈប់នៅសៀមរាប១យប់ ។

ដានីៈ កាលហ្នឹងអ៊ំៗ ប្ដូរមេៗមកជាមួយដែលអត់?

អុលៈ អត់ទេ បែកបាក់គ្នាតាំងពីហ្នឹង ។

ដានីៈ មកឈប់នៅសៀមរាប ឈប់នៅជាមួយពីណា?

អុលៈ ឈប់មួយភ្លែត ឈប់ដេកក្នុងព្រៃដែល មិនមែនក្នុងក្រុងណា ។

ដានីៈ អីចឹងមកដល់កន្លែងស្ពាច់យើងចោលឡានទៅ យើងឡានទៅខាងណា? ឡើងភ្នំ?

អុលៈ បាទ! ឡើងភ្នំ ។

ដានីៈ ឡើងកន្លែងណា?

អុលៈ ឡើងមកគោល៨វិញ បកមកកើតដើរឡើងភ្នំ ។

ដានីៈ ដើរកន្លែងណា?

អុលៈ	គោល៨ ។

ដានីៈ	គោល៨នៅកន្លែងណា?

អុលៈ	នៅខាងលិច ។

ដានីៈ	ជិតអូរស្វាច់?

អុលៈ	ខាងកើតអូរស្វាច់ ។

ដានីៈ	គេហៅគោល៨?

អុលៈ	បាទ!

ដានីៈ	យើងដើរមកណាវិញ?

អុលៈ	ដើរមកកើតទៀត ដើរមករហូតបានទៅនៅ១០០២ ។

ដានីៈ	ដើរពីហ្នឹងមកនៅ១០០២?

អុលៈ	បាទ! ចេញពី១០០២បានបកពីលិចវិញមកនៅ១០០៣វិញទៀត បកចុះបកឡើង ។

ដានីៈ	កាលហ្នឹងដើរហ្នឹងដើរតែក្រុមគ្នាយើងដដែល ឬចូលជាមួយគេ ជាមួយឯង?

អុលៈ	ចូលជាមួយគេ ។

ដានីៈ	កាលហ្នឹងចូលជាមួយពីណាទៅ?

អុលៈ	ចូលជាមួយពួកខ្មែរមានជ័យ ។

ដានីៈ	ពីណាគេមេកាលហ្នឹង?

អុលៈ	តាសឿន ។

ដានីៈ	តាសឿន រថក្រោះហ្នឹង?

អុលៈ	បាទ! ចូលជាមួយគាត់ ។

ដានីៈ	ដល់ពេលចូលទៅយើងបង្កើតជាកងពលនៅ?

អុលៈ	នៅទេ ។

ដានីៈ	ពេលដែលយើងឡើងកន្លែងគោល៨ បានជួបតាសឿន នៅ?

អុលៈ	នៅទេ ។

ដានីៈ	អត់ទាន់ជួបទេ?

អុលៈ	បាទ!

ដានីៈ	មកជួបតាសឿន នៅណា?

អុលៈ	មកជួបនៅ៨០៨វិញ ។

ដានី៖ កន្លែងនេះរាងស្មុគស្មាញបន្តិច ខ្ញុំអត់ច្បាស់ ចាំមើលនេះផែនទីភ្នំដងរែក នេះគោល៨ ហើយយើងដើរពីគោល៨មកណា?

អុល៖ មកខាងកើត។

ដានី៖ ដើរខាងកើត?

អុល៖ មិនមែនគោល៨ទេ ៨០៨មក១០០២។

ដានី៖ អីចឹង៨០៨កន្លែងណាទៅ?

អុល៖ លិច។

ដានី៖ បើគិតមកដល់ឥឡូវក្នុងស្រុកអី ហើយក្នុងឃុំអីយើងគិតមកទល់មុខគ្នា កន្លែងណា?

អុល៖ ៨០៨?

ដានី៖ បាទ! ៨០៨។

អុល៖ ស្រុកអន្លង់វែង។

ដានី៖ ក្នុងឃុំអី?

អុល៖ អត់ដឹងឃុំអីផង។

ដានី៖ ស្រុកអន្លង់វែង ច្រកជាំស្រុកអន្លង់វែងដែរ?

អុល៖ ហ្នឹងហើយជាំស្រុកអន្លង់វែង នៅកើត មិនដឹងចំឃុំអីអត់ស្គាល់ឃុំគេ។

ដានី៖ នៅលើជាំយើងចុះមកជើងភ្នំស្រះឈូក នៅទល់មុខជាំ ដល់ពេល៨០៨?

អុល៖ នៅខាងកើតហ្នឹងបន្តិច។

ដានី៖ ខាងណា? នៅអូរអជ្រៃ?

អុល៖ មិនមែនអូរអជ្រៃទេ អូរអជ្រៃចេញពីនេះទៅអន្លង់វែង។

ដានី៖ យើងជិះពីនេះទៅដល់អន្លង់វែង អន្លង់វែងហើយអូរអជ្រៃ, ត្រពាំងតាវ, ទួលស្វាយ?

អុល៖ ហ្នឹងហើយទៅចំខាងកើតស្រះឈូក ត្រពាំងតាវ ៨០៨ត្រពាំងតាវហ្នឹង។

ដានី៖ ដល់ពេលឈប់ឡានហើយយើងឡើងមកត្រពាំងតាវ៨០៨ ហើយដើរមក១០០២ នៅណា?

អុល៖ ១០០២អានសេះ។

ដានី៖ កន្លែងទីតាំងជំរុំ១០០២អានសេះហ្នឹងតែម្តង?

អុល៖ បាទ!

ដានី៖ កាលហ្នឹងមកជួបពីណាអានសេះ?

អុល៖ ជួបពួកអ៊ំខៀវ។

ដានី៖ ជួបអ៊ំខៀវ នៅអានសេះហ្នឹង?

អុលៈ បាទ!

ដានី៖ អ៊ំខៀវ អ៊ំសុន សេន ហ្នឹង?

អុលៈ បាទ!

ដានី៖ កាលជំនាន់ហ្នឹងគេហៅអ៊ំខៀវ?

អុលៈ បាទ!

ដានី៖ ហើយកាលហ្នឹងគាត់នៅដឹកនាំនៅ១០០២ហ្នឹង?

អុលៈ បាទ!

ដានី៖ ជួបតែអ៊ំខៀវមួយទេ អ៊ំផ្សេងៗមានជួបគាត់ទេ?

អុលៈ អត់បានជួបអស់ទេ ជួបគាត់ហើយនិងតាមុត, តាវ៉ែន ។

ដានី៖ តាវ៉ែន, អ៊ុង វ៉ែន យើងហ្នឹង?

អុលៈ តាវ៉ែន កូនប្រសារតាមុត ។

ដានី៖ កូនប្រសារតាម៉ុក?

អុលៈ កូនប្រសារតាមុត ។

ដានី៖ តាមុត កូនប្រសារតាម៉ុក?

អុលៈ តាមុត កូនប្រសារតាម៉ុក, តាវ៉ែន កូនប្រសារតាមុត ប្តូប្អូនថ្លៃទេ ។

ដានី៖ ជួបអ៊ំខៀវ, ជួបតាមុត, ជួបតាវ៉ែន នៅ១០០២?

អុលៈ បាទ! ហើយនៅបានប៉ុន្មានខែទេ ខ្ញុំមកនៅ១០០៣ ។

ដានី៖ ១០០៣នៅខាងនេះវិញ ។

អុលៈ ១០០៣មុខយើង ។

ដានី៖ មុខអន្លង់វែង?

អុលៈ អត់ទេ អន្លង់វែងទេ មុខទំនប់ដាច់យើងនេះ ។

ដានី៖ កន្លែងអីគេហ្នឹងជប់រុន?

អុលៈ ជប់រុន ។

ដានី៖ ជប់រុនអីចឹងកន្លែង១០០៣?

អុលៈ បាទ!

ដានី៖ មិនមែនទៅកន្លែងដាំទេ?

អុលៈ អត់ទេ ។

ដានី៖ ហ្នឹង១០០៣ហើយកន្លែងហ្នឹង?

អុល៖ បាទ! ១០០៣ ។

ដានី៖ ចុះ១០០១នៅកន្លែងណា?

អុល៖ ១០០១នៅកើត ទន្លេល្មៅ មុំ៣ ថៃ ខ្មែរយើងហើយនិងលាវ ។

ដានី៖ ប៉ុន្តែខាងលោកពូអត់មានទៅដល់១០០១ទេ?

អុល៖ អត់ដល់ទេ ។

ដានី៖ ត្រឹមតែអានសេះ?

អុល៖ បាទ! ត្រឹម១០០២បកមក១០០៣វិញ ។

ដានី៖ បកមក១០០៣វិញ?

អុល៖ បាទ!

ដានី៖ ពេលដែលយើងចេញពី៨០៨ មកអានសេះយើងអត់ទាន់មានកងពលទេ?

អុល៖ នៅឡើយទេ ។

ដានី៖ ប៉ុន្តែដើរទៅជាមួយក្រុមតាសឿននៅឧត្តរមានជ័យហ្នឹង ជួបតាសឿន នៅណា?

អុល៖ ជួបនៅ៨០៨ ។

ដានី៖ ជួបនៅ៨០៨ហើយដើរទៅទាំងអស់គ្នា?

អុល៖ បាទ!

ដានី៖ តាសឿន កាលហ្នឹងគាត់មានកងពលដែលអត់?

អុល៖ មាន កងពលប៉ុន្មាន អត់សួរចំណាំដែរ ជួបបានមួយភ្លែតៗ ។

ដានី៖ ដល់ពេលយើងមក១០០៣ ពីណាដឹកនាំនៅ១០០៣ធំជាងគេ?

អុល៖ ១០០៣តាម៉ុក ។

ដានី៖ មក១០០៣គេឲ្យមកនៅជាមួយតាម៉ុក វិញ?

អុល៖ បាទ! នៅជាមួយតាម៉ុក នៅជាមួយតាមុត ហ្នឹងឯង ។

ដានី៖ ដល់ពេលមកនៅ១០០៣ មានកងពលអត់?

អុល៖ មាន ។

ដានី៖ មក១០០៣ មកនៅកងពលលេខប៉ុន្មានទៅហ្នឹង?

អុល៖ ១០០៣កងពលលេខ៦១៦ ។

ដានី៖ ៦១៦កើតក្រោយ?

អុល៖ ក្រោយ ដែលមកនៅនេះហើយ ។

ដានី៖ តែ១០០៣ដំបូងដែលលោកពូដើរចេញពី៨០៨ មក១០០២-១០០៣មកនៅជាមួយគាម៉ុក កងពលលេខប៉ុន្មាន?

អុល៖ កងពលលេខប៉ុន្មានទេ កងពលធំៗ

ដានី៖ កងពលអន្តរាគមន៍?

អុល៖ បាទ!

ដានី៖ ៩៨០?

អុល៖ ខ្ញុំនៅជាមួយគាម៉ុក, គាមុត នេះគេបំបែកទៅកងពលតូចហើយ កងពលតូចវានៅ៦១៦

ដានី៖ អីចឹងមក១០០៣វិញមកនៅក្នុងកងពល?

អុល៖ ៦១៦ៗ

ដានី៖ ចុះតាសឿន?

អុល៖ តាសឿន ទៅនៅ៨០៨វិញៗ

ដានី៖ ត្រឡប់មក៨០៨វិញ?

អុល៖ បាទ!

ដានី៖ មកធ្វើអីនៅ៨០៨វិញ?

អុល៖ ៨០៨គាត់មកកន្លែងកងពលៗ

ដានី៖ លោកពូអត់ដែលលឺកងពល៩៨០ទេ?

អុល៖ ៩៨០ក្រែងតាមុត? ៩៨០លឺគេថាមិនដឹងកងពលណាៗ

ដានី៖ លោកពូអត់ដែលស្គាល់តាស៊ីម នៅភូមិទួលចារទេ?

អុល៖ តាស៊ីម ស្គាល់ៗ តាស៊ីមហ្នឹងនៅ៩៨០ៗ

ដានី៖ តាស៊ីម ដំបូងនៅ៩៨០?

អុល៖ មិនដឹងគាត់នៅណា ខ្ញុំអត់ចាំៗ

ដានី៖ ដំបូងពេលលោកពូត្រឡប់ពីអានសេះ មក១០០៣វិញ អីចឹងបានន័យថាពេលដែលយើងដើរពី៨០៨មក១០០២រយៈយូរ?

អុល៖ យូរ ៣-៤ថ្ងៃៗ

ដានី៖ ប៉ុន្តែយើងបែកភ្នំពេញខែ១ ឆ្នាំ៧៩ ពេលដែលលោកពូជិះឡាន២យប់ មកដល់កន្លែងផ្លូវបារាំងចាស់ ហើយឡើង?

អុល៖ ឡើងមក៨០៨នេះ ហើយមកនេះទៀត មក១០០២ គេឈប់នៅ១០០២, ១០០១ ទៅនោះ ពួកសឿន ទៅ៨០៨វិញ បានមកនៅកងពល៦១៦ៗ

ដានី៖ ដល់ពេលហ្នឹង មកនៅកងពល៦១៦កាលហ្នឹងពីណាគេធ្វើប្រធានដំបូងបំផុត?

អុល៖ តាញ៉ន ។

ដានី៖ តាញ៉ន ដំបូងគេបំផុត?

អុល៖ បាទ!

ដានី៖ អនុគាត់ពីណាគេ?

អុល៖ ចុន ហើយបានតាឡេ ។

ដានី៖ ហើយលោកពូនៅកន្លែងណាទៅ? នៅជាមួយពីណា?

អុល៖ នៅជាមួយតាឡេ ។

ដានី៖ កាលហ្នឹងមានវរៈអីច្រើនទេ? មានវរសេនាធំអត់?

អុល៖ មាន ។

ដានី៖ មានវរសេនាធំលេខប៉ុន្មានខ្លះកាលហ្នឹង?

អុល៖ វរសេនាធំ១៧, ១៦, ១៨, ១៥ ។

ដានី៖ ៤វរសេនាធំ?

អុល៖ ៥, វរសេនាធំ៥១ ។

ដានី៖ វរសេនាធំ៥១ទៀត?

អុល៖ បាទ!

ដានី៖ ច្រើនវរសេនាធំដែរ?

អុល៖ បាទ!

ដានី៖ មាន៥វរសេនាធំទាំងអស់?

អុល៖ បាទ! តែមនុស្សតិចៗ ។

ដានី៖ គណៈកងពលមានតាញ៉ន, តាចុន, តាឡេ?

អុល៖ បាទ!

ដានី៖ វរសេនាធំកាលហ្នឹងពីណាគេ?

អុល៖ តាវឿន ។

ដានី៖ តាវឿន លេខប៉ុន្មាន?

អុល៖ តាវឿន ១៧ ។

ដានី៖ តាវឿន?

អុល៖ តាវឿន នៅអន្លង់វែង ។ តាវឿន-យាយរ៉ូន ។

ដានី៖ ១៦?

អុល៖ ១៦មានតាម៉េត។

ដានី៖ តាម៉េត?

អុល៖ នៅលិច។

ដានី៖ ឥឡូវ?

អុល៖ បាទ!

ដានី៖ នៅលិចនៅណា?

អុល៖ នៅម៉ាឡៃ-ប៉ៃលិន។

ដានី៖ នៅម៉ាឡៃ ឬប៉ៃលិន?

អុល៖ នៅម៉ាឡៃ ឬប៉ៃលិនអត់ដឹង គេចេញពីនេះទៅអត់ដឹងគេនៅត្រង់ណា។

ដានី៖ ចុះខាង១៨?

អុល៖ ១៨តាចាយ។

ដានី៖ តាចាយណាទៅ?

អុល៖ តាចាយ ស្លាប់បាត់។

ដានី៖ តាចាយ គាត់មកពីខាងបាត់ដំបង?

អុល៖ អត់ទេ មកពីព្រះវិហារ។

ដានី៖ ចុះ១៥?

អុល៖ ១៥ តាកុយ។

ដានី៖ គាត់នៅណាដែលឥឡូវ?

អុល៖ នៅលិចដូចគ្នា។

ដានី៖ នៅម៉ាឡៃ ឬនៅប៉ៃលិន?

អុល៖ នៅម៉ាឡៃ។

ដានី៖ តាកុយ ប្រពន្ធគាត់ឈ្មោះអី?

អុល៖ អត់ស្គាល់ទេប្រពន្ធគាត់។

ដានី៖ តាម៉េត?

អុល៖ តាម៉េត ប្រពន្ធគាត់ឈ្មោះរួន។

ដានី៖ នេះឈ្មោះរ៉ូន ហើយប្រពន្ធតាម៉េត ឈ្មោះរួន?

អុល៖ បាទ! រួន។

ដានី:	បងប្អូនជាមួយយាយរ៉ូន?

អុលៈ	អត់ទេ យាយរួន នេះអ្នកព្រះវិហារយើង ។

ដានី:	តាវឿន?

អុលៈ	យាយរ៉ូន ។

ដានី:	តាវឿន គាត់ដូចមានជំងឺឆ្កួតជ្រូក គាត់ប្រកាច់មួយសារៗ ហ្នឹងឬមិនមែន?

អុលៈ	ហ្នឹងហើយតាវឿន ។

ដានី:	ឥឡូវគាត់នៅព្រះវិហារធ្វើកងទ័ពនៅព្រះវិហារ ឬអត់ទេ?

អុលៈ	អត់ដឹងម៉េច មិនដឹងគាត់នៅទាហានឬអត់សព្វថ្ងៃ ។

ដានី:	ចុះ៥១?

អុលៈ	៥១ចង់ភ្លេចអស់ ។ ៥១បងសារួន ស្លាប់បាត់ហើយ ។

ដានី:	ទើបតែស្លាប់ ឬស្លាប់យូរហើយ?

អុលៈ	ស្លាប់យូរហើយ ។

ដានី:	កាលហ្នឹង៦១៦យើងធ្វើប្រតិបត្តិការកន្លែងណាទៅកន្លែងណា? ទីតាំង?

អុលៈ	ធ្វើចាប់ពីព្រះវិហារទៅកំពង់ធំ ។

ដានី:	ព្រះវិហារស្រុកណាខ្លះ? យើងធ្វើប្រតិបត្តិការហ្នឹង?

អុលៈ	ស្រុកសង្គមថ្មី, ស្រុកគូលែន តែ២ស្រុក ។

ដានី:	តែ២ស្រុកហ្នឹងទេ? ខាងកំពង់ធំ?

អុលៈ	កំពង់ធំធ្វើស្រុកស្ទោង, ស្រុកកំពង់ស្វាយ, ស្រុកសាលាវិស័យ ។

ដានី:	ហើយខាងសង្គមថ្មី ខាងវរសេនាធំលេខណាទៅដែលទៅសង្គមថ្មី?

អុលៈ	១៥, ១៧ ។ ២វរសេនាធំ ។

ដានី:	គូលែន?

អុលៈ	ស្រុកគូលែន ១៦, ១៨ ។

ដានី:	ចុះខាងស្ទោងនេះវិញ?

អុលៈ	ស្ទោង១៥ ។

ដានី:	១៥មានសង្គមថ្មីដែរ?

អុលៈ	១៥សង្គមថ្មី ហើយ៥១ ។

ដានី:	ស្ទោង៥១?

អុលៈ	បាទ! ៥១ តែមួយវរសេនាធំទេទៅនោះ ។

ដានី៖ ទៅខាងកំពង់ធំតែ១វរសេនាធំទេ?

អុល៖ បាទ! មួយវរសេនាធំ ។

ដានី៖ ចុះមានស្ទោង, មានកំពង់ស្វាយ, មានសាលាវិស័យ?

អុល៖ ហ្នឹងចល័ត គ្រាន់តែទៅមួយឆាវ ។

ដានី៖ សន្ធមថ្មី ហើយនិងគូលែនទៅដាប់?

អុល៖ ដាប់ ។

ដានី៖ កាលហ្នឹងមន្ទីរកងពលនៅណាទៅ?

អុល៖ មន្ទីរកងពល ។

ដានី៖ កងពល៦១៦ តាញ៉ន, តាចុន, តាឡេ?

អុល៖ មន្ទីរកងពលនៅលើភ្នំ ។

ដានី៖ នៅ១០០៣នេះទេ?

អុល៖ បាទ!

ដានី៖ ចុះលោកពូនៅណា?

អុល៖ កាលហ្នឹងខ្ញុំនៅក្នុង តាមគាត់ ។

ដានី៖ តាមតាឡេ?

អុល៖ បាទ!

ដានី៖ តាឡេ គាត់អត់នៅលើភ្នំអីចឹង?

អុល៖ អត់ទេ ។

ដានី៖ គាត់ទៅនៅណាវិញ?

អុល៖ ចុះទៅធ្វើការ ។

ដានី៖ តែគាត់គណៈកងពល?

អុល៖ បាទ!

ដានី៖ គណៈកងពលគាត់មានក្តាប់លើវរសេនាធំទៀតទេ?

អុល៖ មាន ។

ដានី៖ គាត់ក្តាប់លើវរសេនាធំណាខ្លះ?

អុល៖ វរសេនាធំ១៨ ហើយ១៦ ។

ដានី៖ ១៨, ១៦ នៅគូលែន?

អុល៖ បាទ!

ដានី:	ចុះ១៥ ហើយ១៧?

អុលៈ	តាញ៉ែន ។

ដានី:	តាញ៉ែន គាត់ស្លាប់?

អុលៈ	បាទ!

ដានី:	ចុះ៥១?

អុលៈ	តាចុន ។

ដានី:	តាចុន ហើយតាឡេ ពីណាធំជាង?

អុលៈ	តាចុន ។

ដានី:	តែតាចុន គាត់កាន់តែមួយវរៈហ្នឹង?

អុលៈ	កាន់១វរៈតែទៅឆ្ងាយ ។ ជិតៗគ្នាតាញ៉ែន ហើយនិងតាឡេ ។

ដានី:	ហើយលោកពូតួនាទីស្អីគេកាលហ្នឹង?

អុលៈ	ក្រុមនីរសា ។

ដានី:	ក្រុមនីរសារបស់តាឡេ?

អុលៈ	បាទ! របស់តាឡេ ។

ដានី:	ប៉ុន្មាននាក់កាលហ្នឹងក្រុមនីរសាររបស់តាឡេ?

អុលៈ	១០នាក់ ។

ដានី:	អីចឹងពីឆ្នាំប៉ុន្មានទៅដែលលោកពូចុះទៅខាងគូលែន ខាងសង្គមថ្មី?

អុលៈ	តាំងពីពេទ្យ ។

ដានី:	៧៩យើងរត់មក?

អុលៈ	៧៩រត់មក ៨២-៨៣រហូត ។

ដានី:	កាលពី៧៩, ៨០, ៨១ នៅណាទៅ?

អុលៈ	នៅលើភ្នំ ។

ដានី:	អត់ធ្វើសកម្មភាពអីនៅឡើយទេ?

អុលៈ	ធ្វើខ្លះ តែខ្លះគេបានចុះ ខ្លះគេអត់បានចុះ តាំងពី៨១ហ្នឹងឯងចុះ គ្រាន់តែយើងដល់ភ្នំរៀបរយកន្លែងបានហើយគេឲ្យចុះធ្វើការខាងក្នុង ។

ដានី:	កងពលនេះពីណាគេអ្នកបង្កើត ដាក់ឈ្មោះ៦១៦អីចឹង?

អុលៈ	តាម៉ុក ។

ដានី:	តាម៉ុក អ្នកបង្កើតដាក់៦១៦អីចឹងតែម្តង?

អុលៈ បាទ!

ដានីៈ តាចុន កាលពីមុនគាត់នៅណាទៅ?

អុលៈ តាចុន នៅណាទេ តែដល់នេះគេចេះតែចាប់បញ្ចូលគ្នា ។

ដានីៈ តាចុន នៅរស់អត់?

អុលៈ នៅលិច ។

ដានីៈ នៅខាងណា?

អុលៈ នៅម៉ាឡៃ-សំឡូត ។

ដានីៈ តាចុន ម៉ាឡៃ-សំឡូត?

អុលៈ តែបងវឿន ដែលនៅអន្លង់វែង ក្រៅពីហ្នឹងទៅនៅលិចៗអស់ ។

ដានីៈ ប្រពន្ធគាត់ឈ្មោះអីតាចុន?

អុលៈ តាចុន កាលហ្នឹងអត់ទាន់មានប្រពន្ធ ។

ដានីៈ គេហៅតាចុនៗអីចឹង?

អុលៈ បាទ!

ដានីៈ មានឈ្មោះអីផ្សេងគាត់?

អុលៈ អត់ស្គាល់ ស្គាល់តែប៉ុណ្ណឹងឈ្មោះគាត់ ។

ដានីៈ តាញ៉ន ឥឡូវគាត់នៅសៀមរាប?

អុលៈ មិនដឹងនៅណា ប្រពន្ធ កូនគាត់នៅថ្កូវ ។

ដានីៈ ថ្កូវនៅណា?

អុលៈ ផ្កាវ ។

ដានីៈ ប្រពន្ធគាត់ឈ្មោះអី?

អុលៈ អត់ស្គាល់ទេប្រពន្ធគាត់ ។

ដានីៈ គាត់ឈ្មោះ ប៉ុល ញ៉ន ពិការដៃ?

អុលៈ អត់ទេ តាញ៉ន អត់ឃើញពិការទេ ។

ដានីៈ អីចឹងលោកពូទៅធ្វើសកម្មភាពនៅខាងកូលែនដល់ពេលណា?

អុលៈ តាំងពី៨២-៨៣រហូត ។

ដានីៈ យើងវៃជាមួយយួន វៃជាមួយទាហានខាងក្នុង?

អុលៈ វៃជាមួយយួន ជាមួយទាហាន ។

ដានីៈ យើងវៃម៉េចទៅកាលហ្នឹង? យើងវៃឈ្នះគេដែរ? កាន់កាប់បានច្រើនដែរ?

អុលៈ	អត់ទេ វៃរត់ៗ ។

ដានីៈ	យើងវៃគេហើយរត់ខ្លួនឯង?

អុលៈ	បាទ! សង្គ្រាមដាក់មីន វៃកាន់កាប់កន្លែងណាអត់មានទេ ។

ដានីៈ	កាលហ្នឹងនៅខាងគូលែន នៅខាងកោះកេរ្តិ៍ ប្រាសាទកោះកេរ្តិ៍ ខាងតំបន់កោះកេរ្តិ៍ខាងកង ពលលោកពូនៅហ្នឹងដែលអត់?

អុលៈ	នៅហ្នឹង តែវរសេនាធំខុសគ្នា ។

ដានីៈ	កាលហ្នឹងវរសេនាធំខុសគ្នា?

អុលៈ	បាទ!

ដានីៈ	កាលហ្នឹងលោកពូមានប្រពន្ធនៅ?

អុលៈ	នៅទេ ។

ដានីៈ	លោកពូពេលវៃមានដែលត្រូវរបួសទេ?

អុលៈ	កាលពីមុនអត់ទេ កាលវៃមុនផ្តាច់ខ្លួន ។

ដានីៈ	វៃពីឆ្នាំណា?

អុលៈ	ពេលខ្ញុំរបួស?

ដានីៈ	បាទ!

អុលៈ	៩៧-៩៨មុនយើងផ្តាច់ខ្លួនបន្តិចហ្នឹង ។

ដានីៈ	៩៨ជិតផុតសង្គ្រាមហើយ?

អុលៈ	បាទ! ជិតផុតហើយ ជិតឆាប់ ។

ដានីៈ	ត្រូវណាខ្លះ?

អុលៈ	ដេកពេទ្យស្រុកថៃ៦ខែ ក្បាលនេះ ខ្លួន ។

ដានីៈ	ត្រូវរបួសអំបែងអីទៅ?

អុលៈ	ត្រូវបេ៩០ ។

ដានីៈ	៦ខែ?

អុលៈ	បាទ!

ដានីៈ	ឥឡូវជាដាច់ទេ?

អុលៈ	ជាហើយ ។

ដានីៈ	លោកពូកងពល៦១៦ហ្នឹងដែលពូថាធ្វើសកម្មភាពនៅខាងព្រះវិហារ ហើយនិងកំពង់ធំមួយ ចំនួនយើងធ្វើរហូតដល់ឆ្នាំណាទៅ?

អុលៈ	រហូតទាល់តែយើងផ្តាច់ខ្លួន ។

ដានីៈ	តែលោកពូមានផ្លាស់ប្តូរអីម៉េច?

អុលៈ	ផ្លាស់ប្តូរមួយវរសេនាធំ១៨ ផ្លាស់មកនៅកងពល៦១២វិញ ។

ដានីៈ	ឆ្នាំណាហ្នឹង?

អុលៈ	ឆ្នាំ៨៧ ។

ដានីៈ	មូលហេតុអីបានយើងផ្លាស់ប្តូរឆ្នាំ៨៧ យើងផ្លាស់ប្តូរហ្នឹង?

អុលៈ	មកគេបាញ់របួសតាឡេ ។

ដានីៈ	លោកពូអាចរៀបរាប់កន្លែងហ្នឹងបន្តិច យ៉ាងម៉េចបានគេបាញ់តាឡេ? ហើយយ៉ាងម៉េចបានគេផ្លាស់ប្តូរវរសេនាធំ១៨មកចូលជាមួយកងពល៦១២វិញ?

អុលៈ	កាលហ្នឹងគាត់នៅកាន់ឃ្លាំងនៅក្រោយ ឃ្លាំងដឹកជញ្ជូន ដល់អីចឹងគាត់អាចធំជាងតាញ៉ន គាត់ឡើងធំជាតាញ៉ន ដល់អីចឹងគេមិនទុកចិត្តគេដាក់ បាញ់ចោល ។

ដានីៈ	ក្នាងងហ្នឹងបាញ់ចោល?

អុលៈ	បាទ! ក្នាងង ។

ដានីៈ	អីចឹងដល់ពេលឆ្នាំ៨៧គេដកគាត់ពីសមរភូមិឲ្យមកកាន់ឃ្លាំងវិញ?

អុលៈ	បាទ! ឃ្លាំងដឹកជញ្ជូន ។

ដានីៈ	កាន់ឃ្លាំងនៅណាទៅ?

អុលៈ	ឃ្លាំងដឹកជញ្ជូនពីតាម៉ុក មក ។

ដានីៈ	ឃ្លាំងដឹកជញ្ជូនរបស់តាម៉ុក?

អុលៈ	បាទ!

ដានីៈ	អីចឹងគាត់ឡើងមក១០០៣វិញ?

អុលៈ	បាទ! គាត់ឡើងធំ ។

ដានីៈ	គាត់ឡើង១០០៣ លោកពូមកអត់?

អុលៈ	អត់ទេ ខ្ញុំនៅតាមកងវិញ ។

ដានីៈ	លោកពូមានតួនាទីអីវិញទៅកាលហ្នឹង?

អុលៈ	កាលហ្នឹងខ្ញុំ អត់មានតួនាទីអីគាត់បំបែកឲ្យមកនៅតាមកងវិញ ។

ដានីៈ	ក្នុងកងអី?

អុលៈ	កង១៨ ។

ដានីៈ	មានតួនាទីជាវរៈអីដែលអត់?

អុលៈ	កាលហ្នឹងឲ្យធ្វើអនុសេនាធំ ។

ដានីៈ	ឲ្យទទួលនៅអនុសេនាធំ?

អុលៈ	បាទ!

ដានីៈ	ហើយគាត់ឡើងមកលើ មកទទួលឃ្លាំងវិញ?

អុលៈ	បាទ! មួយភូមិភាគ មួយច្រកតែម្តង ។

ដានីៈ	មួយច្រក១០០៣? ឃ្លាំងច្រក១០០៣ហ្នឹង?

អុលៈ	បាទ! គាត់ទទួល ។

ដានីៈ	គាត់មកនៅបានយូរទេ?

អុលៈ	នៅបានប្រហែលកន្លះឆ្នាំ ។

ដានីៈ	ហើយលឺព័ត៌មានថាម៉េចទៅ? គាត់នៅបានកន្លះឆ្នាំ?

អុលៈ	ព័ត៌មានមិនដឹងម៉េច គេប្រណែន របៀបថាមុនក្រោមគេ ដល់គាត់នៅលើគេ គេមិនសុខចិត្ត ។

ដានីៈ	ហ្នឹងលោកពូដឹងតាមម៉េច? ម៉េចបានដឹងថាគេប្រណែនហើយគេមិនសុខចិត្ត?

អុលៈ	ចុះបាញ់គ្នាឯង បើមិនថាអីចឹង ។

ដានីៈ	លោកពូដឹងថាពីក្រុមណាអ្នកបាញ់គាត់?

អុលៈ	ក្រុមហ្នឹងពីក្រុមតាញ៉ែន ក្រុមមន្ទីរនីរសាតាញ៉ែន ។

ដានីៈ	អ្នកបាញ់គាត់?

អុលៈ	ដល់បាញ់ហើយស្លាប់ ហ្នឹងតាមុត គាត់ហៅមករៀន រៀនៗទៅពួកខ្ញុំសុំបែក បងថានហ្នឹងកងពល ។

ដានីៈ	សៅ ថាន ហ្នឹង?

អុលៈ	ហ្នឹង សុំបែក បែកមកនៅជាំស្លាយើងនេះ កាលហ្នឹងនៅជាំស្លាគេរៀបកងពលមួយ៤១៧ នៅជាមួយកងកុសល ។

ដានីៈ	៤១៧?

អុលៈ	បាទ!

ដានីៈ	កងពលតាជុំ ជាតិ?

អុលៈ	ហ្នឹងហើយ ជាមួយតាកុសល ដេញពីនោះមក បានពួក៦១២មកនៅហ្នឹងដែលបានគេប្របាច់បញ្ចូលគ្នាវិញ ជាមួយតាហឿន ហ្នឹង ។

ដានីៈ	អីចឹងដំបូងឡើយពេលដែលតាឡេ ស្លាប់ទៅ គេបាញ់ស្លាប់ទៅគេហៅប្រជុំ?

អុលៈ ហ្នឹងហើយ ។

ដានីៈ កាលហ្នឹងតាមុត នៅ១០០៣ទេ?

អុលៈ កាលហ្នឹងនៅ១០០៣ ។

ដានីៈ គាត់អត់ទាន់ទៅខាងសំឡូត-កោះកុងទេ?

អុលៈ នៅទេ ។

ដានីៈ ឆ្នាំណាហ្នឹង?

អុលៈ ៨៧ ។

ដានីៈ ដល់ពេលឪពុកមាលោកពូស្លាប់ តាឡេ ស្លាប់ គេមានរកខុសត្រូវឲ្យអត់?

អុលៈ រកខុសត្រូវហ្នឹងគេហៅរៀន ហៅរៀនទៅពួកដែលបាញ់ដឹងខ្លួនគេចទៅនៅជំរំបារ៉ាំ ខាង ស៊ើន សាន ។

ដានីៈ ទៅនៅជំរំស៊ើន សាន វិញ?

អុលៈ បាទ!

ដានីៈ ពីណាខ្លះដែលទៅពួចាំទេ?

អុលៈ អត់សូវស្គាល់គេប៉ុន្មានទេ ។

ដានីៈ ចុះតាញ៉ន គាត់អត់មាន?

អុលៈ គាត់មានស្អីគាត់ គាត់អត់មានរត់ទៅណា ។

ដានីៈ ចុះបើក្រុមគាត់ ពូថាគាត់អ្នកប្រណែន ដូចថាតាឡេ គាត់ឡើងធ្វើ?

អុលៈ ក្រុមនីរសាគេ ក្រុមនីរសាតាញ៉ន ។

ដានីៈ ក្រុមនីរសាមិនមែនតាញ៉ន អ្នកបញ្ជាឲ្យធ្វើអីចឹងទេ?

អុលៈ មិនមែនទេ មិនដឹងម៉េចអត់សូវដឹង ពួកខ្ញុំថ្ងៃដែលគេបាញ់គាត់ហ្នឹង ខ្ញុំកំពុងដឹកជញ្ជូន ជញ្ជូនគ្រាប់ចុះពីលើភ្នំមកដីខ្មែរ ដល់គេបាញ់ទៅវិញ ក៏គេចាប់ផ្តើមហៅរៀនរកមូលហេតុ រៀនបាន១-២ថ្ងៃ ពួកអ្នកបាញ់គេដឹងខ្លួនវាហ្នឹង វាគេចអស់ទៅ ។

ដានីៈ តាញ៉ន គាត់មករៀនដែលអត់?

អុលៈ តាញ៉ន អត់មករៀនទេ រៀនតែយុទ្ធជន ។

ដានីៈ តែតាមុត ទេអ្នកបង្រៀន?

អុលៈ បាទ! តាមុត ។

ដានីៈ តាមុត និយាយថាម៉េចខ្លះពេលហ្នឹង?

អុលៈ	អត់មាននិយាយថាម៉េច និយាយតែរឿងស្រាវជ្រាវរកអ្នកបាញ់ ខាងណាខុស ខាងណាត្រូវ ។

ដានីៈ	មានបានបាញ់គត្នាអត់?

អុលៈ	អត់ទេ អត់មានបាញ់គទេ គាត់ដេក កូនគាត់ហ្នឹងទើបតែដេកភ្លើងបាន៣ថ្ងៃ នៅផ្ទះគាត់គ្មានអ្នកណាគអីបាញ់គាត់ ។

ដានីៈ	កាលហ្នឹងសៅ ថាន នៅជាមួយគាត់?

អុលៈ	នៅជាមួយគ្នា តែចុះក្នុងអស់ហើយ ។

ដានីៈ	កាលហ្នឹងសៅ ថាន គាត់នៅក្នុងវរៈ១៨?

អុលៈ	ហ្នឹងហើយ ។

ដានីៈ	កាលហ្នឹងគាត់ជាប្រធានវរៈឬក៏កាលហ្នឹង ឬតាចាយ នៅប្រធាននៅឡើយ?

អុលៈ	គាត់កងពលតូច ។

ដានីៈ	ពីណាគេ?

អុលៈ	លោកសៅ ថាន ។

ដានីៈ	កងពលតូចយ៉ាងម៉េចខ្ញុំអត់ទាន់យល់ ព្រោះកាលហ្នឹងមានបែកវរៈ១៥, ១៦, ១៧, ១៨ និង៥១ ។

អុលៈ	ហ្នឹង គាត់នៅវរៈ១៨ហ្នឹងឯង ។

ដានីៈ	កាលហ្នឹងគាត់ធ្វើប្រធាន ឬតាចាយ ប្រធាន?

អុលៈ	តាចាយ ប្រធាន ។

ដានីៈ	អនុពីណាគេ?

អុលៈ	បងសារូន ។

ដានីៈ	បងសារូន ក្រែងនៅ៥១ ។

អុលៈ	នោះមួយទៀត ពីរ ។

ដានីៈ	ពីរនាក់សារូន ដូចគ្នា?

អុលៈ	បាទ!

ដានីៈ	ប៉ុន្តែកាលហ្នឹង សៅ ថាន គាត់នៅណា? អត់ទាន់វរសេនាធំទេ?

អុលៈ	វរសេនាធំហើយ ។

ដានីៈ	គាត់នៅជាមួយពីណាខ្លះ?

អុលៈ	នៅជាមួយតាចាយ ជាមួយតាសួន ។

ដានី៖ ហើយពូវ៉ាន់ កុសល គាត់អត់មាននៅក្នុងហ្នឹងដែរទេ?

អុល៖ បងវ៉ាន់ កុសល កងពល។

ដានី៖ គាត់នៅណា? នៅក្នុងកងពលអីដែរ? ៦១៦ដែរ?

អុល៖ បងកុសល?

ដានី៖ បាទ!

អុល៖ នៅ៦១៧។

ដានី៖ លោកពូម៉ិញនិយាយថាសៅ ថាន នេះគាត់អត់សុខចិត្តទេបំបែក។

អុល៖ បងកុសល?

ដានី៖ សៅ ថាន?

អុល៖ បងថាន នៅក្នុង៦១៦ អីចឹងសៅ ថាន បំបែកមកនៅជាំស្វា ឯបងកុសល គាត់នៅកងពល៦១៧ កងពលចាស់គាត់ ដល់ពេលពួកខ្ញុំបំបែកពីនោះមកយកបងកុសល ទៅគ្រប់គ្រងពួកខ្ញុំ និងបងថាន។ នៅនោះរៀបមួយកងពលមានបងកុសល, ជាត, តាភឿន, មានលោកថាន។

ដានី៖ ឈ្មោះកងពល៤១៧?

អុល៖ បាទ! ៤១៧ ក្នុងនោះវរសេនាធំគឺបែកចេញគ្នាអស់បានគេបំបែកមក ដាក់១៨មកតាចាយ ប្រធានដដែលទេ ហើយវរសេនាធំ១៨។ វរសេនាធំ១៧មានតាកុយ។

ដានី៖ តាកុយ ១៥ មក១៧វិញ?

អុល៖ តាកុយមួយទៀត តាកុយ នៅទំនប់ដាច់។

ដានី៖ ឥឡូវហ្នឹង? តាកុយ នៅទំនប់ដាច់ឥឡូវហ្នឹង?

អុល៖ បាទ! តាកុយ ១៩ ដល់បំបែកកងពលថ្មី តាកុយវរសេនាធំ១៩។

ដានី៖ អីចឹងខ្ញុំបកទៅក្រោយបន្តិច អីចឹងឆ្នាំ៨៧ប្រជុំអីហើយ ដោយសារមានការទំនាស់គ្នាវរសេនាធំ១៨នេះសុំបំបែកចេញពីវរសេនាធំ១៦ ឬខាងលើគេឲ្យបំបែក?

អុល៖ ពួកខ្ញុំសុំហើយគេឲ្យបំបែកតែម្ដង ដល់សុំគេទៅគេឲ្យបំបែក។

ដានី៖ គេឲ្យបំបែក អីចឹងក្នុង៥វរសេនាធំបំបែកតែមួយនេះទេ? តែ១៨នេះមួយទេ?

អុល៖ បាទ! បំបែកតែ១៨មួយទេ។

ដានី៖ ក្រៅពីហ្នឹង១៥, ១៦, ១៧, ៥១ គេនៅដដែល? នៅកងពល៦១៦ដដែល?

អុល៖ បាទ!

ដានី៖ កាលហ្នឹងតាឡេ ផុតទៅពីណាឡើងជំនួសជាគណៈកងពល៦១៦?

អុលៈ		កងពល៦១៦តាកុយ ។

ដានីៈ		មានតាញ៉ែន, តាចុន, តាកុយ?

អុលៈ		បាទ! តាញ៉ែន, តាចុន, តាកុយ ។

ដានីៈ		តាចុន គាត់នៅដដែល?

អុលៈ		ដដែល ។

ដានីៈ		តាវឿន ក៏អត់ទាន់ឡើងគណៈកងពលទេ?

អុលៈ		តាវឿន បែកទៅបាត់ហើយ បែកទៅទំនប់៧៨៥ ។

ដានីៈ		តាវឿន បែកទៅ៧៨៥វិញ?

អុលៈ		បាទ! បែកទៅកងពល៧៨៥ ។

ដានីៈ		គាត់ធ្វើប្រធាន ឬអត់ទេ?

អុលៈ		ប្រធានមិនដឹងពីណា មិនដឹងតាស័ន ឬតាវឿន ពីរនាក់ហ្នឹង ។

ដានីៈ		តាស័ន នេះហ្នឹង?

អុលៈ		តាស័ន ស្រុកយើង ពួក៧៨៥ហើយហ្នឹង ។

ដានីៈ		ហើយនេះវរៈ១៧ ពីណាឡើងជំនួសទៅ?

អុលៈ		អត់ដឹងព្រោះបែកគ្នាអស់ហើយ ។

ដានីៈ		ដល់ពេលឆ្នាំ៨៧ហ្នឹងវរសេនាធំយើងនេះ វរសេនាធំ១៨សុំប្តូរមក៦១២វិញ?

អុលៈ		បាទ! មកកងពល៦១២ ។

ដានីៈ		នេះមកនៅដាំស្វាវិញ?

អុលៈ		បាទ! នៅដាំស្វា ក្រោយ១០០៣ ។

ដានីៈ		ដាំស្វាហ្នឹងកន្លែងដប់រុនដែលអត់ទេ?

អុលៈ		ហ្នឹងហើយ ចុះមកដប់រុន ។

ដានីៈ		ដាំស្វាដីថៃ?

អុលៈ		ដីថៃ ។

ដានីៈ		អីចឹងមកដាំស្វាយើងមកចូលជាមួយកងពល៦១២?

អុលៈ		ជាមួយបងហឿន ។

ដានីៈ		នៅដាំស្វា?

អុលៈ		បាទ!

ដានីៈ		ជាមួយតាហឿន?

អុលៈ បាទ!

ដានីៈ តាហឿន គាត់ធ្វើប្រធានធំ?

អុលៈ បាទ! ប្រធានធំ។

ដានីៈ អនុគាត់?

អុលៈ អនុគាត់តាកង, តាដាត, តាមឿន, បងថាន។

ដានីៈ សៅ ថាន។

អុលៈ សៅ មឿន, សៅ ថាន។

ដានីៈ បងប្អូនគាត់?

អុលៈ អត់ទេ អត់បងប្អូនទេ តែត្រកូលដូចគ្នា។

ដានីៈ ឈ្មោះស្អីដាត?

អុលៈ អត់ស្គាល់ទេ ស្គាល់តែឈ្មោះគាត់។

ដានីៈ តាដាត, តាកង?

អុលៈ បាទ!

ដានីៈ ពូកុសល កាលហ្នឹងគាត់អត់ក្នុងឋានៈហ្នឹងទេ?

អុលៈ បងកុសល ដែរ ចង់ភ្លេចបងកុសល។

ដានីៈ ដល់ពេលមក៦១៧មានប៉ុន្មានវរៈទៅ? វរសេនាធំប៉ុន្មានទៅ?

អុលៈ ១៧, ១៨, ១៩។

ដានីៈ តែ៣ហ្នឹងទេ?

អុលៈ តែ៣ទេ។

ដានីៈ មានតែ៣ ១៧, ១៨, ១៩ ពីណាប្រធានវរៈ១៧?

អុលៈ ១៩ តាកុយ។

ដានីៈ តាកុយមួយផ្សេងពីតាកុយ មុន?

អុលៈ បាទ!

ដានីៈ មិនមែនតាកុយ១៥?

អុលៈ មិនមែន។

ដានីៈ តាកុយ នេះសព្វថ្ងៃគាត់នៅ?

អុលៈ ទំនប់ដាច់។

ដានីៈ នៅភូមិទំនប់ដាច់?

អុលៈ បាទ!

ដានីៈ ប្រពន្ធគាត់ឈ្មោះអីតាកុយ?

អុលៈ ឈ្មោះភាព។

ដានីៈ តាកុយ-យាយភាព នៅទំនប់ដាច់។

អុលៈ បាទ!

ដានីៈ ចុះ១៨?

អុលៈ ១៨ តាដេត។

ដានីៈ នៅណាដែល?

អុលៈ នៅទំនប់ខ្មោរ។

ដានីៈ នៅឃុំអីគេ?

អុលៈ ឃុំត្រពាំងប្រាសាទ។

ដានីៈ ទំនប់ខ្មោរ?

អុលៈ បាទ!

ដានីៈ ប្រពន្ធគាត់ឈ្មោះយាយអី?

អុលៈ សូត្រ។

ដានីៈ គាត់នៅទំនប់ខ្មោរទាំងពីរនាក់?

អុលៈ បាទ!

ដានីៈ ចុះ១៧?

អុលៈ ១៧ អ៊ុក ឆុន។

ដានីៈ គាត់នៅណាឥឡូវ?

អុលៈ គាត់ទាហាន។

ដានីៈ គាត់ទាហាននៅខាង?

អុលៈ នៅប្រាសាទព្រះវិហារ។

ដានីៈ ហើយលោកពូនៅណាវិញ? មកចូលនៅក្នុងនេះ ឬក្នុងនេះ?

អុលៈ នៅក្នុងវរៈ១៨។

ដានីៈ វរៈ១៨ ដល់ពេលហ្នឹងលោកពូជាអីវិញ មកកាន់វរៈ?

អុលៈ អនុសេនាធំ។

ដានីៈ ហ្នឹងឆ្នាំ៨៧ហើយ?

អុលៈ បាទ!

ដានីៈ ពេលដែលតាឡេ ឪពុកមាលោកពូគេបាញ់ស្លាប់ទៅមកក្នុងនេះវិញ?

អុលៈ បាទ!

ដានីៈ លោកពូមកនៅណាវិញ? មកឈរជើងនៅណាវិញ?

អុលៈ នៅជាំស្លានេះ យើងធ្វើការនៅស្រុកសង្គមថ្មី។

ដានីៈ មកធ្វើការនៅស្រុកសង្គមថ្មីទៀត?

អុលៈ បាទ!

ដានីៈ នេះកងពល៦១២ធ្វើការនៅខាងខេត្តណាខ្លះ?

អុលៈ ៦១២ធ្វើតែព្រះវិហារមួយមុខ។

ដានីៈ ស្រុកអីខ្លះទៅកាលហ្នឹង?

អុលៈ ស្រុកគូលែន, មានស្រុកសង្គមថ្មី ពីរស្រុកប៉ុណ្ណឹងឯង តាមព្រំដែន។

ដានីៈ ព្រំដែនណា?

អុលៈ អានសេះនៅក្នុងស្រុកជាំក្សាន្ត។

ដានីៈ ណាទៀត?

អុលៈ ប៉ុណ្ណឹង។

ដានីៈ កងពលតែ៣ហ្នឹងទេ?

អុលៈ បាទ!

ដានីៈ ខាងសង្គមថ្មីវរៈណាត្រូវទៅហ្នឹង?

អុលៈ សង្គមថ្មីមាន១៨, ១៧ ។ ១៩ ធ្វើការនៅជាំក្សាន្ត។

ដានីៈ ចុះគូលែន?

អុលៈ គូលែន១៧ សង្គមថ្មីវរសេនាធំ១៨។

ដានីៈ លោកពូនៅខាងសង្គមថ្មី ឈរជើងនៅម្តុំណា?

អុលៈ សង្គមថ្មីនៅម្តុំភូមិសំឡាយ, ក្បាលខ្លា, ភូមិតាបោះ។

ដានីៈ ខាងនេះពីណាដឹកនាំទៅ?

អុលៈ តាដេត។

ដានីៈ ចុះតាហឿន, តាកង, តាផាត, តាមឿន, តាថាន អីអត់ទៅ?

អុលៈ ១៨ មានលោកសៅ ថាន ទៅ, ១៩ បងកុសល, ១៧ តាហឿន។

ដានីៈ តាហឿន គាត់ដឹកនាំផ្ទាល់ទៅ?

អុលៈ បាទ!

ដានីៈ ហើយនិងប្រធានវរសេនាធំ តាឌុន ៗ ចុះតាផាត, តាមឿន, តាកង អីគាត់អត់ទៅណាទេ?

អុលៈ កុំរទៅពួកហ្នឹង ៗ

ដានីៈ គាត់នៅណាពួកហ្នឹង?

អុលៈ ច្រើននៅជាមួយមីងៗ តាកង នៅកន្ទែងឃ្លាំង ៗ

ដានីៈ តាផាត?

អុលៈ តាផាត នៅក្រោយ ៗ

ដានីៈ តាមឿន?

អុលៈ ខាងដឹកជញ្ជូនពួកនោះ ដឹកជញ្ជូនគ្រាប់ ៗ

ដានីៈ ហើយលោកពូចុះទៅសន្តមថ្មីដល់ឆ្នាំណា?

អុលៈ សន្តមថ្មី៩១-៩៣ ៗ

ដានីៈ ៩១-៩៣គេបោះឆ្នោតនៅ? គេបោះឆ្នោតពេលអ៊ុនតាក់ចូលមក?

អុលៈ អ៊ុនតាក់ចូលមកក៏នៅហ្នឹងដែរ ៗ

ដានីៈ នៅសន្តមថ្មីដែរ?

អុលៈ នៅសន្តមថ្មី ៗ

ដានីៈ គេបោះឆ្នោតលើកទី១ក៏នៅហ្នឹងដែរ?

អុលៈ បាទ!

ដានីៈ លោកពូការឆ្នាំណាទៅអីចឹង?

អុលៈ ខ្ញុំការ៨៤ ៗ

ដានីៈ ការនៅណា?

អុលៈ ការនៅលើគេហៅអូរធំ ៗ

ដានីៈ នៅណាទៅអូរធំ?

អុលៈ នៅដីថៃ ៗ

ដានីៈ អូរធំមុំណា?

អុលៈ នៅលិច នៅគេហៅស្ទឹកេត្រង់នោះ ភូមិស្ទឹទេ ៗ

ដានីៈ នៅក្បែរៗអូរគ្រាវ, ដងទង់, ស៊ឹងចាន់, ចងក, អូរធំនៅក្បែរៗហ្នឹងឬឆ្ងាយពីហ្នឹង?

អុលៈ អូរធំនៅក្បែរៗហ្នឹង ៗ

ដានីៈ ជិតដាំស្វា?

អុលៈ ជិតទៅអូរត្រាវ ។

ដានីៈ ប្រពន្ធលោកពូអ្នកនៅខាងអី?

អុលៈ ដឹកជញ្ជូនរបស់កងពលហ្នឹង ។

ដានីៈ កងពល៦១៦ ឬ៦១២?

អុលៈ កងពល៦១៦ ។

ដានីៈ ដល់ពេលការហើយលោកពូផ្លាស់កងពល៦១២ គាត់មកដែរ?

អុលៈ មកទាំងអស់គ្នា ។

ដានីៈ មកនៅដាំស្វាវិញ?

អុលៈ បាទ!

ដានីៈ ដល់ពេលលោកពូចុះទៅខាងសន្គមថ្មី គាត់នៅណា?

អុលៈ នៅលើភ្នំ ។

ដានីៈ នៅកន្លែងម្តុំណា?

អុលៈ នៅដាំស្វា ។

ដានីៈ អីចឹងកងពលរបស់លោកពូ៦១២នេះ លោកពូថាយើងធ្វើនៅស្រុកសន្គមថ្មី ស្រុកគូលែន អានសេះ បានន័យថាយើងចាប់ពីដាំស្វាបុកមកខាងអានសេះ?

អុលៈ បាទ!

ដានីៈ មួយជួរព្រំដែនហ្នឹងកងពល៦១២ទាំងអស់?

អុលៈ បាទ!

ដានីៈ ពីដាំស្វាមកអានសេះតែមួយវរសេនាធំ១៩ទេ?

អុលៈ បាទ! ដល់ពេលគេត្រូវវ៉ៃហៅកំលាំងពីក្នុងមកខ្វះ ។

ដានីៈ ប៉ុន្តែយើងចាប់ផ្តើមនៅស្រុក ពីព្រំដែនពីឆ្នាំ៨៧ឬមានកំលាំងគេពីមុនមក?

អុលៈ កំលាំងគេពីមុន កំលាំងមុនកងពលតាហឿន ពួក១៧និង១៩ ។

ដានីៈ តែកាលលោកពូនៅក្នុងកងពល៦១៦ មានចុះទៅខាងសន្គមថ្មី, ខាងគូលែន អីចឹងជាន់ជាមួយកងពលនេះដែរ?

អុលៈ អត់ទេ កងពលនេះនៅតែព្រំដែនទេ ។

ដានីៈ កាលពីមុនមនៅតែព្រំដែនទេ?

អុលៈ	នៅព្រំដែន ។ ពួកខ្ញុំមកនៅជាមួយហ្នឹង បំបែកពួកខ្ញុំពី៦១៦មកនៅ៦១២បានពួកនោះគេទៅកំពង់ធំអស់ ។

ដានីៈ	៦១៦ទៅកំពង់ធំវិញអស់?

អុលៈ	បាទ!

ដានីៈ	ដល់ពេលនេះឲ្យពូបន្តនៅជាមួយ៦១២ តែធ្វើការនៅស្រុក២ជំនួសកន្លែងចាស់៦១៦ហ្នឹងមកនៅវិញ?

អុលៈ	បាទ!

ដានីៈ	យល់ហើយ ។

អុលៈ	ដល់អីចឹង៦១៦គេទៅកំពង់ធំអស់ទៅ ទៅធ្វើការនៅកំពង់ធំ ។

ដានីៈ	ពេលដែលវ៉ៃហ្នឹង ពេលដែលយើងចុះទៅខាងក្នុងយើងធ្វើអីខ្លះតួនាទីរបស់យើង?

អុលៈ	តួនាទីរបស់យើងមានតែណែនាំអប់រំប្រជាពលរដ្ឋ កុំឲ្យវ៉ៃខ្មែរនិងខ្មែរគ្នាឯង ។

ដានីៈ	ម៉េចទៀត?

អុលៈ	មានអីប៉ុណ្ណឹង បាយទឹក បងប្អូនយើងទាំងអស់គ្នា បងវ៉ៃប្អូន ប្អូនវ៉ៃបង វាអត់ត្រូវ វាអត់កើត យើងខំបង្រួបបង្រួមគ្នា កុំវ៉ៃគ្នា កុំឈ្លោះគ្នា ការងារអត់មានអីទេ មានតែប៉ុណ្ណឹង ។

ដានីៈ	មានតែប៉ុណ្ណឹងទេ?

អុលៈ	បាទ!

ដានីៈ	ចុះទាហានខាងក្នុងយើងទៅធ្វើម៉េច? យើងទៅអប់រំគេម៉េចកើត?

អុលៈ	ទាហានយើងអត់អប់រំទេ ។

ដានីៈ	ប៉ះវ៉ៃគ្នា?

អុលៈ	បាទ! ប៉ះវ៉ៃ ជួនកាលវ៉ៃ ជួនកាលឃើញគ្នាគេចចេញ អត់ចង់វ៉ៃគ្នាទេ ។

ដានីៈ	ទាហានខ្មែរៗដូចគ្នាអត់ចង់វ៉ៃទេ?

អុលៈ	បាទ! អត់ចង់វ៉ៃទេ ។

ដានីៈ	បើប៉ះយួន?

អុលៈ	ប៉ះយួនដាក់ហ្នឹងឯង ។

ដានីៈ	ខស្ប្រាហ៍ប៉ះយួនទេ?

អុលៈ	ប៉ះដែរ យូរៗម្តង មិនមែនថាសំដៅវ៉ៃប៉ុន្មានទេ សំដៅការងារប្រជាជនទេ ចៃដន្យជួបគ្នាទេដែលវ៉ៃគ្នា ។

ដានី: បើប្រជាជនយើងទៅឃោសនាដើម្បីឲ្យគាត់ចូលមកខាងយើង ឬយ៉ាងម៉េច? ឬគ្រាន់តែប្រាប់អប់រំគាត់?

អុល: ឲ្យគាត់ជឿជាក់មកខាងយើង។

ដានី: មានគោលការណ៍ប៉ុន្មានខ្លះដែលយើងទៅអប់រំគាត់ យើងទៅនិយាយជាមួយគាត់ យើងមានស្អីខ្លះ? យើងនិយាយថាម៉េចខ្លះ?

អុល: និយាយគ្រាន់តែថា កុំជឿជនជាតិបរទេស ជនជាតិបរទេសកាប់សម្លាប់ខ្មែរគ្នាឯង គេចូលមកសម្លាប់ខ្មែរ យើងអប់រំគាត់ទៅ គាត់មានជំហរមួយថាកងទ័ពព្រៃល្អ ត្រឹមត្រូវ ស្លូតបូតស្រួលបួល ព្រោះតែកាលណាទៅធ្វើការអ៊ីចឹង ជួនកាលមានសារ៉ុងឲ្យសារ៉ុង មានក្រណាត់យើងឲ្យក្រណាត់គាត់ទៅ។

ដានី: យើងមានស្អីឲ្យហ្នឹង?

អុល: បាទ! យើងមានស្អីយើងឲ្យហ្នឹង។

ដានី: គាត់ឲ្យអីមកយើងវិញ?

អុល: គាត់មានអង្ករ យើងធ្វើការក្នុងអ៊ីចឹងប្រហុក, អំបិល, អង្ករ យើងទិញតាមរយៈគាត់ដែរ។

ដានី: យើងមានលុយដែរ?

អុល: គេមានលុយ។

ដានី: ខាងលើឲ្យលុយយើងដែរ?

អុល: បាទ! ខាងលើឲ្យលុយ សារ៉ុង ក្រណាត់។

ដានី: យើងបានលុយអ៊ីចឹងទិញអង្ករ, អំបិល, ប្រហុក ពីគាត់មក?

អុល: បាទ!

ដានី: យើងស្នាក់នៅជាមួយគាត់ក្នុងភូមិហ្នឹង ឬយើងនៅក្នុងព្រៃ?

អុល: យើងនៅក្នុងព្រៃទេ យើងគ្រាន់តែទៅជួបគាត់មួយភ្លែតៗទេ។

ដានី: កងទ័ពអ៊ីចឹងយើងទៅក្នុងភូមិ កងទ័ពខ្លះនៅលីវ អត់ទាន់មានប្រពន្ធ ហើយទៅស្រឡាញ់គាត់ការមានអីចឹងដែលអត់?

អុល: ស្រឡាញ់ ជួនកាលត្រូវគ្នាគេ ការឲ្យនៅនេះទៅ។

ដានី: ការនៅលើនេះ?

អុល: ការនៅលើនេះវិញ។

ដានី: គាត់តាមយើងមកដែរ?

អុល: មាន។

ដានី៖ ប្រជាជនមានតាមមកជាមួយយើងមានច្រើនដែរ?

អុលៈ មកច្រើនដែរ ជួនកាលគាត់នៅក្នុងមិនបាន គេឲ្យមក ខ្មាំងរដ្ឋកម្ពុជាគេចាប់ គាត់មកយើង យើងយកមកទុកលើនេះ ។

ដានី៖ ដល់ពេលនៅហ្នឹងដល់ឆ្នាំ៩៣ ទើបលោកពូដកមកលើវិញ ឬយ៉ាងម៉េច?

អុលៈ ណា?

ដានី៖ លោកពូមានប្រសាសន៍មិញ លោកពូនៅខាងសង្គមថ្មីហ្នឹងរហូតដល់កៅប៉ុន្មាន?

អុលៈ ៩៣-៩៤ ។

ដានី៖ បានមកណាវិញ?

អុលៈ មកនៅអានសេះ ដកទាំងអស់មួយកងពល ។

ដានី៖ មួយកងពលមកនៅអានសេះទាំងអស់?

អុលៈ នៅអានសេះទាំងអស់ ។

ដានី៖ ឈប់នៅជាំស្វា?

អុលៈ ជាំស្វានៅប្រពន្ធកូន តែកំលាំងទ័ពមកនៅអានសេះទាំងអស់ ។

ដានី៖ ប៉ុន្តែកាលហ្នឹងលោកពូនៅសង្គមថ្មី តែប្រពន្ធកូន?

អុលៈ នៅលើ ។

ដានី៖ ប៉ុន្មានថ្ងៃ ប៉ុន្មានខែ យើងមកជួបគ្នាម្តង?

អុលៈ ជួនកាល២ឆ្នាំ ជួនកាល១ឆ្នាំ ជួនកាល៣ឆ្នាំ ។

ដានី៖ យូរណាស់? ជិតគ្នាដែលតាំ?

អុលៈ ជិត តែមិនងាយចុះឡើង ។

ដានី៖ អីចឹងយូរៗជួបគ្នាម្តង?

អុលៈ បាទ!

ដានី៖ ក្រែងឆ្នាំ៨៩-៩០ យើងចុះពីលើមកនៅដីខ្មែរយើងវិញ?

អុលៈ បាទ! យើងចុះ ។

ដានី៖ តាម៉ុក ឈូសផ្លូវនៅជាំចុះមក?

អុលៈ មកជិតទាន់អ៊ុនគាត់ មុនអ៊ុនគាត់មួយឆ្នាំ យើងចុះមកនៅក្រោម ។

ដានី៖ តែលោកពូអត់មកទេ?

អុលៈ យូរៗមកម្តង ។

ដានី៖ តែប្រពន្ធចុះមកនៅណាទៅ?

អុលៈ	នៅច្រកព្រះប្រឡាយ ច្រកជប់រុន ។

ដានីៈ	ច្រកព្រះប្រឡាយ ខាងទំនប់ដាច់ទៅត្រង់?

អុលៈ	បាទ!

ដានីៈ	ប្រពន្ធលោកពូមកនៅហ្នឹងដែរ?

អុលៈ	បាទ!

ដានីៈ	ប៉ុន្តែលោកពូនៅខាងសង្គមថ្មីនោះទេ?

អុលៈ	ខ្ញុំនៅធ្វើការក្នុង ។

ដានីៈ	យូរៗចុះមកម្តង?

អុលៈ	បាទ! យូរៗមកម្តង ។

ដានីៈ	ដល់ឆ្នាំ៩៣-៩៤ដែលថាប្រមូលកំលាំងទៅនៅអានសេះវិញ?

អុលៈ	ជិតផ្តាច់ខ្លួន ៩៧ ។

ដានីៈ	ចាំមើលយើង ។

អុលៈ	៩៨យើងផ្តាច់ខ្លួន នៅ៩៧មកហ្នឹងទាំងអស់ ប្រពន្ធនៅនេះទេ នៅជើងភ្នំនេះទេ ចុះមកក្រោមអស់ហើយ នៅវៃដាច់អានសេះគេឲ្យនៅហ្នឹងរហូត ។

ដានីៈ	នៅយូរទេ? នៅអានសេះបានរយៈពេលប៉ុន្មានឆ្នាំ?

អុលៈ	នៅ៦ខែ ។

ដានីៈ	៦ខែទេ?

អុលៈ	បាទ!

ដានីៈ	អ៊ីចឹងលោកពូមានប្រសាសន៍មិញថាមកនោះឆ្នាំ៩៨ ។ មកពីសង្គមថ្មីមកកៅប៉ុន្មាន?

អុលៈ	៩៧ដែរ ។

ដានីៈ	អ៊ីចឹងនៅរហូត នៅខាងក្នុង?

អុលៈ	បាទ! នៅតែក្នុង នៅព្រំដែនបាន៦ខែហ្នឹង ។

ដានីៈ	តែអានសេះយើងវៃបានយូរនៅ?

អុលៈ	បាន៦ខែ ។

ដានីៈ	ទើបតែបានថ្មីៗដែរ?

អុលៈ	បាទ!

ដានីៈ	កាលមុនខាងរដ្ឋាភិបាលអ្នកកាន់កាប់ទេនៅអានសេះ?

អុលៈ	មុនរដ្ឋាភិបាល ។

ដានី: ដែលថាកងពលរបស់លោកពូនៅពីជាំស្វា មកអានសេះហ្នឹង អីចឹងយើងគ្រាន់តែនៅចេះទេ ខាងរដ្ឋាភិបាលកាន់កន្លែងអានសេះរបស់គេទេ?

អុល: របស់គេទេ ។

ដានី: យើងវ៉ៃអត់បែកទេ? វ៉ៃទៅ វ៉ៃមក?

អុល: បាទ! វ៉ៃទៅ វ៉ៃមក ។

ដានី: ដល់ពេលជិតឆ្នាំ៩៧បានវ៉ៃបាន?

អុល: បានវ៉ៃបាន បាននៅ៦ខែគេវ៉ៃបានវិញ ។

ដានី: ដែលលោកពូថាត្រូវរបួសហ្នឹង?

អុល: ហ្នឹងហើយ ។

ដានី: កាលហ្នឹងវ៉ៃនៅអានសេះ?

អុល: វ៉ៃនៅអានសេះ ។

ដានី: ឆ្នាំកៅប៉ុន្មានទៅ?

អុល: ៩៧ ។

ដានី: វ៉ៃត្រូវរបួស ។ ពេលដែលខ្មែរក្រហមចាប់ផ្ដើមបែកបាក់គ្នា ចាប់ផ្ដើមឈ្លោះគ្នា កាលហ្នឹងលោកពូនៅណា?

អុល: នៅអានសេះធ្វើការក្រោម ។

ដានី: ធ្វើការក្រោមទេ?

អុល: ធ្វើការក្រោមស្រុកសន្ដមថ្មី ។

ដានី: អីចឹងពេលដែលតាសុនសេន ស្លាប់ លោកពូនៅកន្លែងណា?

អុល: នៅស្រុកសន្ដមថ្មីនៅឡើយទេ ។

ដានី: នៅសន្ដមថ្មីនៅឡើយទេ?

អុល: បាទ!

ដានី: ខាងតា០៥, តាប៉ុល ពត ខាងតាម៉ុក ចាប់អីហ្នឹងក៏នៅខាងសន្ដមថ្មីនៅឡើយទេ?

អុល: បាទ! ខ្ញុំនៅធ្វើការដីក្នុង ឯប្រពន្ធកូននៅនេះ ។

ដានី: យ៉ាងម៉េចដែរលោកពូដឹងរឿងអត់ទាក់ទង?

អុល: អត់ដឹងរឿងទេ ។

ដានី: បើតាមយោបល់លោកពូយ៉ាងម៉េចដែលបានគាត់បែកបាក់គ្នា?

អុល: អត់ដឹងម៉េច ខ្ញុំអត់សួរយល់ អត់សួរដឹង ។

ដានី: ខាងណាខុស ខាងណាត្រូវ ទាក់ទងរឿងឈ្មោះ? ក្រោយមកតា០៥, ០៦ តាម៉ុក ចាប់យកទៅសម្លាប់?

អុល: ខ្ញុំអត់សូវយល់ អត់សូវដឹង ព្រោះនៅធ្វើការខាងក្នុងជួនកាល១-២ឆ្នាំបានឡើងមកម្តង អត់សូវដឹង នឹកឃើញថាយើងធ្វើការក្នុងហ្នឹង យើងមកម្តងចេះគេផ្តល់ថវិការល្មម២-៣ឆ្នាំស្រេច ។

ដានី: លោកពូចូលសមាហរណកម្មឆ្នាំណាទៅ?

អុល: ៩៨ ។

ដានី: ពេលហ្នឹងលោកពូជាពីរបួសនៅ?

អុល: ជាហើយ ។

ដានី: ជាហើយយូរទេបានចូល?

អុល: ជាបានមួយខែ ។

ដានី: ចុះពេលដែលលោកពូថាយើងវៃរបួសនៅអានសេះ កាលហ្នឹងខាងរដ្ឋាភិបាលវៃបានវិញ?

អុល: បាទ!

ដានី: វៃបានវិញត្រូវរបួស?

អុល: បាទ!

ដានី: កាលហ្នឹងខាងតាជុំ ជាតិ, តាជា កែវ គាត់ទៅចូលជាមួយរដ្ឋាភិបាលនៅ? ពេលដែលយើងវៃនៅអានសេះដែលរដ្ឋាភិបាលវៃយកវិញ?

អុល: គាត់ទៅហើយ ។

ដានី: អីចឹងកងពលលោកពូខាងជាមួយតាម៉ុកទេ?

អុល: ជាមួយតាម៉ុក ។

ដានី: យើងបែកជាមួយខាងតាជា កែវ, កងពលគាត់ផ្សេង?

អុល: ជាមួយតាម៉ុក ដូចគ្នា ។

ដានី: យ៉ាងម៉េចដែលលោកពូខ្ញុំអត់សូវច្បាស់កន្លែងហ្នឹង?

អុល: តាកែវ, តាជុំ នៅជាមួយតាម៉ុកហ្នឹងឯង ដល់គេព្រឹត្តិការណ៍ចាប់០៥, ០៦ គាត់គេចទៅក្នុង ។

ដានី: យ៉ាងម៉េចវិញទៅ?

អុលៈ	ទៅក្នុងគាត់មកឃោសនានេះវិញ យើងដឹងថាគាត់ទៅនោះអស់ នេះរាងអត់សូវស្រួល យើងផ្លាច់ខ្លួនចូលទៅរដ្ឋកម្ពុជាថាឈ្មះ អីចឹងរដ្ឋកម្ពុជាថាអត់មានអ្នកណាឈ្នះ អត់មានអ្នកណាចាញ់គឺឈ្នះទាំងអស់គ្នា យកពាក្យស្លោកហ្នឹងមកបានយើងសំរួលគ្នារហូត ។

ដានីៈ	ពេលដែលវ៉ៃនៅអានសេះហ្នឹងកាលហ្នឹងខាងតាជុំ, តាកែវ អត់មានចូលរួមជាមួយរដ្ឋាភិបាលវ៉ៃជាមួយពួកពូ ឬអត់ទេ?

អុលៈ	កាលហ្នឹងគាត់អត់ទាន់ទៅទេ ។ គាត់អត់ទាន់ទេ វ៉ៃមុនហ្នឹងទៀត ។

ដានីៈ	វ៉ៃមុនហ្នឹងយូរទេ?

អុលៈ	មិនយូរទេ កន្លះឆ្នាំ ។

ដានីៈ	ខាងរដ្ឋាភិបាលគេវ៉ៃយកបានវិញ?

អុលៈ	បាទ!

ដានីៈ	ខាងយើងវ៉ៃយកបានរយៈពេលប៉ុន្មានបានគេមកវ៉ៃយកវិញបាន?

ដានីៈ	រយៈពេល៦ខែ ។

អុលៈ	យើងវ៉ៃបាន៦ខែគេមកវ៉ៃយកវិញ?

អុលៈ	បាទ! វ៉ៃយកវិញ ។

ដានីៈ	កាលហ្នឹងពូត្រូវរបួសស្លាប់ច្រើនអត់?

អុលៈ	ស្លាប់មួយ របួស៣-៤នាក់ ។

ដានីៈ	កាលហ្នឹងកងទ័ព៦១២នៅហ្នឹងពេញកងពលតែម្តង?

អុលៈ	បាទ! ពេញ ។

ដានីៈ	ខាងគេមកវ៉ៃប៉ុន្មានកងពលទៅ?

អុលៈ	មិនដឹងប៉ុន្មានខាងរដ្ឋកម្ពុជា ។

ដានីៈ	ច្រើន?

អុលៈ	គេមានរថក្រោះ មានកាំភ្លើងធំ ហើយយើងមានស្អី យើងអត់មានស្អីនឹងគេផង ។

ដានីៈ	វ៉ៃរយៈពេលប៉ុន្មានបានយើងដកចេញពីអានសេះ?

អុលៈ	អានសេះ នៅទ្រាំទ្រគ្រាប់កាំភ្លើងទេ គាំងពីវ៉ៃឈ្នះអត់ដែលនេះ គេវ៉ៃតវិញរហូត ។

ដានីៈ	របេះរបោះ?

អុលៈ	របេះរបោះ គេវ៉ៃអត់ទាន់ឈ្នះយើង ទាល់តែមានរថក្រោះ គេដាក់ខ្លាំងបានយើងថយ ។

ដានីៈ	យើងមកនៅណាវិញពេលគេវ៉ៃបាន?

អុលៈ	គេវ៉ៃបានយើងនៅនេះវិញ នៅតាមហ្នឹងឯង នៅព្រះប្រឡាយ ជប់រុន ។

ដានី៖ ដល់ពេលតាជុំ, តាកែវ គាត់ទៅជាមួយរដ្ឋាភិបាលទៅ ខាងតាហឿន គាត់ទៅខាងតាម៉ុក វិញ?

អុល៖ នៅជាមួយតាម៉ុក ដល់គាត់មកមួយសារពីនោះមកត្រូវរ៉ូវគ្នាបានចូលទាំងអស់គ្នា ។

ដានី៖ តែតាម៉ុក គាត់ឡើងទៅខាងភូណាយ?

អុល៖ តាម៉ុក ឡើងភ្នំពួកខ្ញុំអត់ទៅទេ ទៅតែតាម៉ុក ទៅតែមួយប៉ែកគ្នាគាត់ ទៅតិច ពួកខ្ញុំនៅនេះទាំងអស់ ចូលមករដ្ឋកម្ពុជាទាំងអស់ ។

ដានី៖ ចូលមកជាមួយរដ្ឋកម្ពុជាទៅ?

អុល៖ បាទ!

ដានី៖ ចូលហើយមានបានទៅរ៉ៃតាម៉ុក ដែលអត់ទេ?

អុល៖ អត់ទេ អត់បានទៅរ៉ៃ គេអត់រ៉ៃយើង យើងអត់ទៅរ៉ៃគេ ។

ដានី៖ តែកាលជំនាន់តាជុំ, តាកែវ គាត់ទៅនាំទ័ពរាជរដ្ឋាភិបាលចូលមករ៉ៃ?

អុល៖ ចូលមកតែយើងអត់បានទៅជាមួយគេទេ ។

ដានី៖ យើងឈប់រ៉ៃហើយ?

អុល៖ ឈប់ហើយ ។

ដានី៖ ទៅជួយខាងតាម៉ុក ក៏អត់? ជួយខាងរដ្ឋាភិបាលក៏អត់?

អុល៖ អត់ដែរ ។

ដានី៖ យើងគ្រាន់តែចូលជាមួយគេ យើងនៅស្ងៀម?

អុល៖ នៅស្ងៀម ។

ដានី៖ ដូចតាហឿន ក៏គាត់នៅស្ងៀម?

អុល៖ នៅស្ងៀម ។

ដានី៖ ថ្ងៃនេះហើយ ម៉ោងជិត១ លោកពូហេវ អីចឹងខ្ញុំអរគុណច្រើនលោកពូដែលបានផ្តល់បទសម្ភាសន៍ជាមួយខ្ញុំជិត២ម៉ោងហើយ ខ្ញុំអរគុណច្រើន លោកពូហេវ ។

អុល៖ អត់ហេវទេ តែខ្លីអភ័យទោសផង មិនដឹងខុស ត្រូវ លើសលោះយ៉ាងណា ។

ដានី៖ អត់អីទេ អត់មានអីទេ បទពិសោធន៍លោកពូបានជំរាបខ្ញុំនេះ ខ្ញុំយកទៅស្តាប់ យកទៅផ្ទៀងផ្ទាត់ជាមួយអ៊ំ ពូ មីងផ្សេងៗទៀត ហើយយើងយកមកសរសេរ កន្លែងណាដែលសំខាន់ៗយើងសរសេរ កន្លែងណាជាន់គ្នាអត់អីដែរ ។ ខ្ញុំអរគុណលោកពូច្រើន ។

អុល៖ បាទ!

ចប់